
PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
Life Insurance ធានារ៉ាប់រងជីវិត
Car Insurance ធានារ៉ាប់រងរថយន្ត
Refinance Your Debts រៀបចំសងប្រាក់ជំពាក់ឡើងវិញ
Investments វិនិយោគទុន
Office or Home Appointment. ជួបនៅការិយាល័យយើង ឬនៅផ្ទះលោកអ្នកក៏បាន
We also provide translation and interpretation services.
យើងផ្តល់ការបកប្រែភាសា តាមក្រដាស ឬផ្ទាល់មាត់
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034



# ខ្មែរប៉ុស្តិ៍ The Khmer Post



ហាងមាសរស្មី
SUNSHINE JEWELRY INC
•Fine Jewelry
•Certified Diamonds & Custom Design
មានលក់គ្រឿង អលង្ការ យ៉ាងប្រណិតបំផុត ចេញសញ្ញាបត្រធានាពេជ្រអាច ផ្លាក់ ឬ ថ្លៃ មាស ប្រាក់ ពេជ្រ ជូនតាមបំណង ។
យើងមានបទពិសោធន៍ ១៥ឆ្នាំ ហើយមានកេរ្តិ៍ឈ្មោះល្អក្នុងការបំរើសេវាអលង្ការនេះ
702 Washington Avenue Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com



CAMBODIAN-AMERICAN BIWEEKL NEWSPAPER

VOLUME 03 | ISSUE 31 | 27th January-12th March 2009 | ADVERTISING (267) 253-3947 | WWW.THEKHMERPOST.COM


## សាខាគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី នៅហ្វីឡា បើកកិច្ចប្រជុំរួមគ្នា

ខ្មែរប៉ុស្តិ៍ : អ៊ុំ លឿម :

•••សាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋ ផែនស៊ីវ៉េនញៀ ដែលដឹកនាំដោយ លោក ញ៉ុយ ចំរើន និងសាខាគណបក្ស សម រង្ស៊ី (តទៅទំព័រទី២០)

## ទីវាសាំងវ៉ាឡង់តាញខ្មែរ

ដោយ : ពិន សំខុន

•••ទិវាដែលអាមេរិក-អឺរ៉ុប-អូស្ត្រាលី និងអាស៊ី បាននាំគ្នាប្រារព្ធរំលឹកគុណប្រយោជន៍នៃសេចក្តីស្រឡាញ់ គឺពិភពលោកឱ្យន័យធំសម្បើមណាស់ចំពោះជោគជ័យដែលកើតចេញពីសេចក្តីស្រឡាញ់ ឬស្នេហា ។ (តទៅទំព័រទី០៤)

## តុលាការជម្រះក្តីខ្មែរក្រហម : មាស មុត មេដឹកនាំខ្មែរក្រហម ព្រមានពីអស្ថិរភាពនយោបាយ

ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល

•••ក្នុងថ្ងៃបើកសវនាការកាត់ទោសអតីតមេគុកទួលស្លែង (មន្ទីរស-២១) កាលពីពេលថ្មីៗកន្លងមកនេះ និងការជជែកដេញដោលថា ត្រូវនាំខ្លួនជនសង្ស័យបន្ថែមទៀតឬមួយយ៉ាងណានោះ ។ អតីតទាហានជាន់ខ្ពស់ខ្មែរក្រហម មាស មុត បានព្រមានថា ប្រសិនបើមានការនាំខ្លួនជនសង្ស័យបន្ថែមទៀតនោះ (តទៅទំព័រទី១១)


សហចៅក្រមនៃសាលាក្តីខ្មែរក្រហម



Mobile-net
We connect you to the world!
Since 1995
7.5¢
កម្ពុជា
ចុះឈ្មោះថ្ងៃនេះ នឹងទទួលបាន 133 នាទី សំរាប់ទូរស័ព្ទទៅកម្ពុជា ដោយឥតយកកំរៃ !
1.9¢ ថៃឡង់
5.5¢ លាវ
សេវាទូរស័ព្ទអន្តរជាតិ ដ៏ប្រសើរបំផុត
រកភ្នាក់ងារធ្វើការ
គ្មានកាលកំណត់
គ្មានយកកំរៃលើការតភ្ជាប់ប្រព័ន្ធ
គ្មានយកកំរៃលើការថែទាំ
គ្មានតម្លៃប្រែប្រួល
my011.com
1(800) 818-9000


## អតីតអគ្គមេបញ្ជាការកងទ័ព កែ គឹមយ៉ាន ត្រូវចាប់ខ្លួន?

ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ស៊ឹម សុភាឫទ្ធិ

•••បន្ទាប់ពីដកតំណែងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទរួចមក មានព័ត៌មានលេចឮជាច្រើនដែលគួរឱ្យសង្ស័យនោះ បានធ្វើឱ្យអារម្មណ៍មហាជនមានការសោកស្តាយ និងបារម្ភពីសុវត្ថិភាពរបស់លោកអតីតនាយឧត្តមសេនីយ៍ កែ គឹមយ៉ាន យ៉ាងខ្លាំង ។

អ្នកតាមដានសភាពការណ៍នយោបាយក្នុងប្រទេសខ្លះឮថា លោកអតីតអគ្គមេបញ្ជាការត្រូវបានចាប់ខ្លួនដាក់ក្នុងមន្ទីរឃុំឃាំងនៅទីបញ្ជាការកងរាជអាវុធហត្ថ (PM) (តទៅទំព័រទី០៩)


អតីតនាយឧត្តមសេនីយ៍ កែ គឹមយ៉ាន


ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)
ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាលិខិតឆ្លងដែន
សេវាអន្តោប្រវេសន៍ កក់សណ្ឋាគារ ឬជួលឡាន
USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069
Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...

# កូនប្រុសសម្តេច ហ៊ុន សែន ឡើងសក្តិផ្កាយ១

**ខ្មែរប៉ុស្តិ៍ :**

●●●កូនប្រុសច្បងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោក ហ៊ុន ម៉ាណែត ត្រូវបានឡើងឋានន្តរសក្តិជាឧត្តមសេនីយ៍ត្រី (ផ្កាយ១) នៅក្នុងព្រះរាជក្រឹត្យ ដែលឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ សម្តេចបរមនាថ នរោត្តម សីហមុនី កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩ ។ លោក ហ៊ុន ម៉ាណែត មុននេះ គឺជាវរសេនីយ៍ឯក និងជាមេបញ្ជាការកងកម្លាំងប្រឆាំងនឹងភេរវកម្មនៃក្រសួងការពារជាតិ ។ លោក ហ៊ុន ម៉ាណែត ត្រូវបានលោកឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិបំពាក់ឋានន្តរសក្តិជាឧត្តមសេនីយ៍ត្រី កាលពីថ្ងៃទី១២ កុម្ភៈ នៅក្នុងពិធីប្រជុំបូកសរុបការងារ ក្រសួងការពារជាតិ ។ លោក ទៀប ម៉ែន អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិប្រាប់ព្រឹត្តិបត្រឌឹឃែមបូឌាដេលី កាលពីថ្ងៃអាទិត្យ ថា ការដំឡើងបុណ្យសក្តិផ្កាយ១ ដល់លោក ហ៊ុន ម៉ាណែត នេះ គឺមិនមែនដោយសារតែលោកជាកូនប្រុសរបស់សម្តេច ហ៊ុន សែន នោះទេ គឺមកពីលោកធ្វើការបានល្អនៅក្នុងក្រសួង និងថាលោក ហ៊ុន ម៉ាណែត ឡើងបុណ្យសក្តិនេះយឺតណាស់ គឺលោកឡើងសក្តិជាវរសេនីយ៍ត្រីតាំងពីឆ្នាំ២០០៦មកម្ល៉េះ បន្ទាប់ពីបានបញ្ចប់ការសិក្សានៅសាលាបណ្ឌិតសភាយោធាអាមេរិក វ៉េស ផញ្ញ និងបានធ្វើការអស់ពេលជាច្រើនឆ្នាំ ក្នុងក្រសួងការពារជាតិមក ៕



ឧត្តមសេនីយ៍ផ្កាយ៤ ទៀ បាញ់ និង ហ៊ុន ម៉ាណែត កូនប្រុស ហ៊ុន សែន ពាក់ផ្កាយ១ (រូបស្ការ)


## ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
**Jeffrey N. Kale**
Attorney at Law



ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ជូនដល់សហគមន៍ខ្មែរជាង២០ឆ្នាំហើយ .ការិយាល័យ "ច្បាប់ទូទៅ" ដែលមានជំនាញផ្លូវច្បាប់ដូចតទៅ:

- គ្រោះថ្នាក់រថយន្ត
- បើកបរក្រោមឥទ្ធិពលញៀន ឬពុល
- មានរបួសនៅកន្លែងធ្វើការ
- ទិញលក់អចលនវត្ថុ
- ច្បាប់បើកក្រុមហ៊ុន
- ច្បាប់ឧក្រិដ្ឋកម្ម
- គ្រោះថ្នាក់ដោយរអិល ឬដួល
- រំលោភច្បាប់លើផ្លូវចរាចរ
- ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**
Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

Car Accidents
DUI/DWI
Workplace Injury
Real Estate
Corporate Law
Criminal Law
Slip & Fall Accidents
Traffic Violations
Collections

សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ នឹងតម្លៃគួរសមអាចមានអ្នកបកប្រែជូនបាន





# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300





សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាប" យើងធ្វើចុះពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៨រូប ដែលមានជំនាញគ្រប់ជ្រុងជ្រោយនៃវិជ្ជាធ្វើធ្មេញ ។

មណ្ឌលធ្មេញឯកទេសខាងការទារលំអរ

**ឯកទេសខាង**

- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហ្វៀតែមួយដែលមានបន្ទប់ពិសោធន៍ នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួសដែលផលិតឡើងតាមគុណភាពដែលលោកអ្នកចង់បានទាំងអស់ សុទ្ធតែដំណើរការដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន ។

**ទន្តសាស្ត្រទូទៅ**

- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្ចិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- **-សំអាតធ្មេញឱ្យស្អាតៈ** ដោយធ្វើដោយឡេស៊័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

ថ្ងៃ ច័ន្ទ : 10am-6pm
ថ្ងៃ អង្គារ : 10am-6pm
ថ្ងៃ ពុធ : 10am-7pm.
ថ្ងៃ ព្រហស្បតិ៍ : 10am-6pm
ថ្ងៃ សុក្រ : 10am-6pm.
ថ្ងៃ សៅរ៍ : 10am-7pm

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

**ចុះថ្លៃ 10% ដល់អ្នកគ្មានប័ណ្ណសុខភាព**

អាចធ្វើផែនការណ៍បង់ប្រាក់រាល់ខែ

# ហ៊ុន សែន កំពង់ធ្វើឱ្យ ជា ស៊ីម ទល់ច្រក ?

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា, ស៊ឹម សុភាឫទ្ធិ**

•••នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ដែលបានប្រកាសកែ្តងៗថា ខ្លួននឹងបន្តកាន់អំណាចអស់មួយជីវិតនោះ បាននឹងកំពុងតែមានទំនាស់ផ្ទៃក្នុងជាមួយនឹងមេបក្សរបស់ខ្លួន ជា ស៊ីម កាន់តែធ្ងន់ធ្ងរ ហើយជំលោះនេះក៏បានបង្ហាញឱ្យឃើញកាន់តែច្បាស់ផងដែរ ។



ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្មែរ



ជា ស៊ីម ប្រធានគណបក្សប្រជាជន

បន្ទាប់ពីដកតំណែងអតីតនាយឧត្តមសេនីយ៍ កែ គីមយ៉ាន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទរួចមក ហ៊ុន សែន បុរសខ្លាំងគ្មានពីរក៏បានបញ្ជាឱ្យដកកងអង្គរក្សរបស់ ជា ស៊ីម ពី600នាក់មកនៅត្រឹម100នាក់ប៉ុណ្ណោះ ។

ទង្វើនេះបានបង្ហាញឱ្យឃើញថា កាលពីអតីតនាយឧត្តមសេនីយ៍ កែ គីមយ៉ាន នៅមានអំណាច ជា ស៊ីម មានកំលាំងយោធានៅក្នុងដៃប្រមាណ60ភាគរយ ពីព្រោះលោក កែ គីមយ៉ាន ជាជនួង របស់លោក ស ខេង ហើយ លោក ស ខេង ជាប្អូនថ្លៃរបស់លោក ជា ស៊ីម ។

អ្នកតាមដានសភាពការណ៍នយោបាយបានបញ្ចេញទស្សនៈប្រហាក់ប្រហែលគ្នាថា ក្រោយពីដកលោក កែ គីមយ៉ាន អំណាចយោធាត្រូវស្ថិតក្នុងដៃ ហ៊ុន សែន ភ្លាម100ភាគរយ ដែលការដកនាយឧត្តមសេនីយ៍ដូចស្តែនោះ ដឹងតែ ហ៊ុន សែន និងព្រះមហាក្សត្រនរោត្តម សីហមុនី ប៉ុណ្ណោះ ។

ប្រភពខាងលើបានអះអាងថា កាលពីអំឡុងឆ្នាំ 1993 អំណាច ជា ស៊ីម ជាមេបក្សមានដល់ 70 ភាគរយ ប៉ុន្តែរដ្ឋប្រហារថ្ងៃទី02 ខែកក្កដា ឆ្នាំ1994 មកមនុស្សជំនិតរបស់ ជា ស៊ីម ត្រូវបានគេបង្ខំឱ្យចាកចេញពីនយោបាយដូចជា ស៊ិន សុង, ស៊ិន សេន ជាដើម ។ ចាប់តាំងពីពេលនោះមក ហ៊ុន សែន បានបន្តក្តោបអំណាចកាន់តែខ្លាំងឡើង ហើយរើសយកមន្ត្រីអាក្រក់ដូចជា ហុក ឡង់ឌី ឱ្យធ្វើព្យុះភ្លៀងកាប់សំលាប់មនុស្សតាមអំពើចិត្ត ។

ហុក ឡងឌី កាលពីនៅរស់បានយកអំណាច ហ៊ុន សែន ពង្រឹងអំណាចក្នុងបក្ស និងបញ្ជាឱ្យគេសំលាប់មនុស្សគ្មានត្រាប្រណី ហើយបន្ទាប់គាត់ស្លាប់ទៅឈ្មោះអាស្រូវរបស់គាត់បានសាយភាយឡើងគួរឱ្យស្អប់ខ្ពើម ។

ប្រភពដែលស្និទ្ធនឹងសែ ជា ស៊ីម បានឱ្យដឹងថា បន្ទាប់ពីដកអង្គរក្ស ជា ស៊ីម មួយភាគធំ ពួកគេគ្មានការងារធ្វើ ហើយខ្លះក៏ត្រូវគេបញ្ជូនទៅតំបន់ផ្សេងៗ ដើម្បីកាត់បន្ថយអំណាចរបស់ ជា ស៊ីម ។

ប្រភពខាងលើបានបន្តថា ជា ស៊ីម និង ហ៊ុន សែន តែងតឹងមាត់កដាក់គ្នាម្តងម្កាល ដោយសារតែចង់ដាក់មន្ត្រីរបស់ខ្លួនកាន់អំណាចឱ្យបានរឹងមាំ ហើយ ហ៊ុន សែន បានដាក់មន្ត្រីរបស់ខ្លួនឱ្យកាន់តំណែង មិនឆ្លងយោបល់ ជា ស៊ីម ក៏មាននិងដកមនុស្សស្និទ្ធរបស់ ជា ស៊ីម មិនសួរយោបល់ក៏មានដែរ ។

ប្រភពខាងលើបានបន្តថា (តទៅទំព័រទី១៤)

## ការសែតខ្មែរប៉ុស្តិ៍ នៅ " រដ្ឋអាឡិន "

❖❖❖លោកអ្នកអាន "ខ្មែរប៉ុស្តិ៍" នៅរដ្ឋអាឡិន អាចអញ្ជើញរកកាសែតរបស់លោកអ្នកបាន នៅ ប្រូវិដិន តាមហាងពាណិជ្ជកម្មដូចតទៅ:

1- ASIAN STAR MARKET
618 ELMWOOD AVENUE
PROVIDENCE RI 02907

2- VIDEO CHHAY SAVANN
384 ELMWOOD AVENUE
PROVIDENCE, RI 02907
Phone :(401)588 9306

3- FRIENDSHIP MARKET
187 MESER STREET
PROVIDENCE, RI 02907
Phone : (401) 274 3744

4- KHMER WORLD VIDEO (KW)
310 RESERVOIR AVENUE
PROViDENCE, RI 02907
Phone : 401- 467 5900

តម្លៃផលិតកាសែត នឹងធ្វើបានកើនឡើងយ៉ាងខ្ពស់ ហេតុនេះ សូមលោកអ្នកអានមេត្តាអធ្យាស្រ័យចំពោះការដាក់តម្លៃ៥0សេន ក្នុងការជាវកាសែតមួយច្បាប់ ចាប់ពីពេលនេះទៅ ។ ទីចាត់ការខ្មែរប៉ុស្តិ៍ ៕


# BALDI FUNERAL HOME

1331 S. Broad St. Philadelphia, Pa 19147

Cell: 267-934-9888 / Tel : 215-389-2414

**សូមសួររកលោក សេខ ឬ** Thomas

### ឈាបណកិច្ចតាមប្រពៃណី

ឈាបណដ្ឋានមានផ្តល់ជូននូវក្តារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្តីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

### ពិធីបូជាសព

"បាល់ឌី" ផ្តល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្តារមឈូសសំរាប់សពទន្ទឹមនោះ មានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិធាតុជាចុងបញ្ចប់។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។





**(Locates in South Philly, convenience traffic, and free parking)**

### Traditional Funeral

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

### Cremation

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

(តមកនៅទំព័រទី០១)

# ទីវាសាំងវ៉ាឡង់តាញ...

តើន័យស្នេហាខ្មែរ មានអត្ថន័យដូចគ្នានឹងស្នេហានៃអ្នកដែលប្រារព្ធ **ទិវាសាំងវ៉ាឡង់តាញ** ដែលទើបនឹងបានធ្វើនាថ្ងៃទី១៤ កុម្ភៈ នេះ ?

"ស្រឡាញ់ផ្អែមនឹងស្អប់ " តែថ្ងៃទី១៤ កុម្ភៈ ២០០៩ នេះ សហគមន៍ខ្មែរ នៅឆ្នេរខាងកើត មានហ្វីឡាដែលហ្វៀ មានវ៉ាស៊ីនតុន មានឡូវែល បានប្រារព្ធពិធីនេះដោយមានការជប់លៀងភោជនាហារ រាំរែក ទាំងអ្នកមានគូរ ទាំងអ្នកគ្មានគូរ យ៉ាងសប្បាយរីករាយ ដោយរាប់ទាំងចាស់ និងក្មេងផង ដូច្នេះ សហគមន៍ខ្មែរ ជាទូទៅបានឱ្យកិត្តិយសដល់សេចក្ដីស្រឡាញ់យ៉ាងខ្ពង់ខ្ពស់ដូចគេឯងឯទៀតដែរ ។

ថ្ងៃដ៏សំខាន់នេះ យើងគួរលើកមកពិចារណាបន្តិចដែរថា តើសេចក្ដីស្រឡាញ់នេះ ជាសីលធម៌ដែរឬទេ ? មែនហើយគ្រប់ការសិក្សាពីមនុស្សសេចក្ដីស្រឡាញ់ប្រាកដជាប្រភពនៃកម្លាំង នៃការរីកចំរើន នៃអំណោយ នៃការព្យាយាមអំណត់ជាប្រាកដ ក៏ប៉ុន្តែគេនៅតែឃើញនៅឡើយថា រនាំងនៃសេចក្ដីស្រឡាញ់ នៅមានច្រើនសន្ធឹកសន្ធាប់នៅឡើយ ។

-ហេតុអ្វីក៏នៅមានការតុំគួនរវាងគូរស្នេហ៍ រហូតដល់ប្រព្រឹត្តអំពើបាបដាក់គ្នាទៅកើត ?

-ហេតុអ្វីក៏មានគូរសង្សារវ័យក្មេងមួយចំនួនសុខចិត្តសម្លាប់ខ្លួន ដោយសារតែនៅមានឪពុកម្ដាយជំទាស់នឹងសេចក្ដីស្នេហារបស់ខ្លួន។

-ហេតុអ្វីក៏យុវនារីខ្លះគ្មានសេចក្ដីក្លាហានគ្រប់គ្រាន់នឹងបង្ហាញពីអារម្មណ៍ស្រឡាញ់របស់ខ្លួន ដល់មនុស្សដែលខ្លួនស្រឡាញ់ជូនកាលចរិកស្ត្រី ឬបុរសគ្រប់លក្ខណ៍នៅព្រៅមួយជីវិតក៏មាន ?

-ហេតុអ្វីក៏ទ្រព្យសម្បត្តិ បុណ្យសក្តិ វណ្ណៈ ពណ៌សម្បុរស្បែក អាចយកជាលេសមកទប់ស្កាត់សេចក្ដីស្នេហាមិនឱ្យកើតមានឡើង..?




ករណីជាបុព្វហេតុរាប់មិនអស់នេះហើយ ដែលកំពុងកើតរីកសុសសាយនៅក្នុងសហគមន៍ខ្មែរសព្វថ្ងៃ ដោយពុំមាននរណា គ្រូបង្រៀនណា ឬព្រឹទ្ធាចារ្យណាហ៊ានលើកករណីទាំងឡាយនោះ មកលាតត្រដាងជាសាធារណៈ សម្រាប់ជាជំនួយដល់ការពិចារណាក្រុមគ្រួសារខ្មែរឡើយទេ ។

❖សេចក្ដីស្រឡាញ់ ឬស្នេហាទាមទារនូវការយោគយល់ ការលួងលោម ការថែទាំ យកអាសារដោយគ្មានចង់ទាមទារអ្វីជាសំណងឡើយ ។ ការដែលចេះតែយកអាសារគ្នានេះហើយ ដែលគេតែងសង្កេតឃើញនៅលើបុគ្គលិកលក្ខណៈនៃមនុស្សស្រី ទោះបីជាបានជាសិទ្ធិស្មើគ្នា ក៏នៅមានមនោសញ្ចេតនាដ៏ជ្រាលជ្រៅជាងបុរស ដែលសម្បូរតែការគិតតែពីផ្លូវភេទ នៅក្នុងបេះដូងរបស់ខ្លួន ។ នេះជាបុព្វហេតុនាំឱ្យសេចក្ដីស្រឡាញ់បានក្លាយទៅជាទាបខ្ពស់ ទៅជាសគុណពេញសិទ្ធិនៃភាគីនីមួយៗមានភាពមិនស្មើគ្នា ហើយត្រូវបានគេគិតថា ជាគុណស្រ័យអ្វីមួយបាននោះ ។

យោងតាមអត្ថន័យដ៏ខ្លីនេះ យើងគួរតែនឹកអាណិតអាសូរដល់អ្នកដែលពុំបានភ្លក្សរសជាតិដ៏ឈ្ងុយឆ្ងាញ់ ដែលពុំអាចបំភ្លេចបានក្នុងជីវិតពីសេចក្ដីស្រឡាញ់ដ៏ស្មោះស្ម័គ្រ ឬក៏បានសេចក្ដីស្រឡាញ់ដ៏សុខដុម ហើយត្រូវបាត់បង់ទៅវិញដោយបុព្វហេតុណាមួយ ។ នេះគឺជាការបាត់បង់រសជាតិនៃជីវិត នៃកម្លាំងពលំនៃមនុស្ស ហើយជាពិសេសការស្រឡាញ់ គឺជាការវិនិយោគដ៏ធំធេងរបស់គ្រួសារ និងរបស់ប្រទេស ដែលខ្លួនរស់នៅ។

❖រីឯការស្រឡាញ់មួយទៀត ដែលបានកើតឡើងជាធម្មជាតិ គឺការស្រឡាញ់រវាងម្ដាយឪពុក និងកូនប្រុសស្រី ឬជីតាជីដូនជាមួយចៅ ឬក៏មាមីងជាមួយកូនក្មួយ ជាសេចក្ដីស្រឡាញ់ ដែលមានន័យផ្អែមពីធម៌ព្រះពុទ្ធ គឺការកើតហើយមិនស្លាប់ទៅវិញទេ ដែលគេអាចរាប់បញ្ចូលទៅក្នុងសេចក្ដីប្រាថ្នារបស់ **ទិវា វ៉ាឡង់តាញ** នោះដែរ ។

សេចក្ដីស្រឡាញ់នេះ មិនត្រឹមតែសំខាន់សម្រាប់ **ទិវាវ៉ាឡង់តាញ** ទេ វាក្លាយទៅជាច្បាប់ដ៏សំខាន់បំផុតសំរាប់ដឹកនាំមនុស្សឱ្យចេះស្រឡាញ់កូនចៅនៅក្មេង ដោយការស្រឡាញ់ ការបីបមថ្នាក់ថ្នម ការពារ និងការប្រៀនប្រដៅបង្រៀនឱ្យក្លាយទៅជាមនុស្សប្រពៃ អាចក្លាយទៅជាអ្នកដឹកនាំសង្គមបាន ។ ជាថ្មីម្តងទៀត យើងសង្កេតឃើញព្រឹត្តិការណ៍ដ៏គួរអាណិតអាសូរបំផុត ដល់កុមារា កុមារីខ្មែរ ដែលត្រូវបញ្ឈប់ការសិក្សានៅមធ្យមសិក្សាស្ទើរទាំងអស់អនាថាចូលរួមសង្គមពាលរាប់មិនអស់ញៀនគ្រឿងពុលស្ទើរគ្រប់គ្នា មានសម្ដាយកូនចៅមុន អាយុគ្រប់ការ ដោយបង់ចិត្ត ដោយគ្មានបំណងការជួយណែនាំ ការពារ ដោយគ្មានការគ្រប់គ្រង ដោយគ្មានមនុស្សដែលមានការស្រឡាញ់ក្នុងខ្លួន។

បាត់បង់ឧត្ដមគតិ " **ទិវា វ៉ាឡង់តាញ** " ចំពោះកុមារ ធ្វើឱ្យដែនដីមហាសេដ្ឋីអាមេរិកាំង ពុំអាចជួយឱ្យមនុស្សតូចទាប ឱ្យអាចទៅជាសំខាន់បានឱ្យមាតាបិតាគ្មានមនុស្សបន្តពូជ បន្តពាណិជ្ជកម្មឱ្យសង្គមគ្រួសារ និងសហគមន៍ខ្លួនឯងគ្មានអនាគតភ្លឺស្វាង ។ ខ្មែរច្រើនណាស់ ពុំបានដឹងទេថា សហរដ្ឋអាមេរិក គេបានធ្វើវិនិយោគធំជាងគេបង្អស់លើវិស័យអប់រំ ជាពិសេសលើការស្រឡាញ់ ថែទាំ ការពារកុមាររាប់ទាំងកុមារខ្មែរផងដែរនោះទេ ។ សំខាន់ជាងគេនេះទៅទៀត គឺនៅតែពុំទាន់បានដឹងថា បើទោះបីជាកំពុងមានការធ្វេះធ្លោយធ្វើខុសជ្រួលទៅហើយក្ដី ក៏ឪពុកម្ដាយនៅតែអាចកែស្ថានភាពនោះឱ្យបានប្រសើរឡើងវិញបាននៅឡើយ ឱ្យតែមានឆន្ទៈមុះមុតថា សេចក្ដីស្រឡាញ់ចំពោះកូនចៅខ្លួននៅមាននៅឡើយទេ ។

❖នៅមានសេចក្ដីស្រឡាញ់មួយទៀត ដែលមនុស្សជាច្រើនយល់ថា " **ទិវា វ៉ាឡង់តាញ** " បានឧទ្ទិសជូនដែរនោះ គឺការស្រឡាញ់រាប់អានជាមិត្តភក្តិដ៏ល្អ ។ គឺជាការស្រឡាញ់រាប់អានដោយមិនប្រកាន់អាយុ ឬពណ៌សម្បុរ មានការគោរពស្មើភាពគ្នា ចេះលើកដំកើងគ្នា បបួលគ្នាធ្វើអំពើល្អ ការពារគ្នាក្នុងលក្ខណៈសីលធម៌ពិចារណារួមគ្នា ។ល។

សង្គមនៃសហរដ្ឋអាមេរិកនេះ តម្រូវឱ្យប្រជាពលរដ្ឋចេះរួមរស់ជាមួយគ្នា ចេះមូលមតិគ្នាកសាង : ភូមិ ស្រុក សាលារៀន អ្នកគ្រប់គ្រងបាន ។

(តទៅទំព័រទី១៦)

NEW GOLDEN PALACE RESTAURANT
801-21 Washington Ave.
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

Authentic Chinese & Vietnamese Cuisine
Very Delicious and Nutritious

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ
**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)
**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon

# ទស្សនៈ "វៀតណាម_កម្ពុជា" "ថ្កោលទោសអង្គការការពារសិទ្ធិមនុស្ស"

**ដោយ : ម៉ម យិន**

•••រដ្ឋាភិបាលកម្ពុជាធ្លាប់បានថ្កោលទោស និងបដិសេធមិនទទួលស្គាល់នូវរបាយការណ៍ស្ដីពីស្ថានភាពសិទ្ធិសេរីភាពមនុស្សដែលរដ្ឋាភិបាលកម្ពុជាបានប្រព្រឹត្តទៅលើប្រជាពលរដ្ឋខ្មែរ ជាបន្តបន្ទាប់មករបស់លោក យ៉ាស្ហហ្កាយ តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហ-ប្រជាជាតិ និងលោក ប្រាដ អាដេម របស់អង្គការការពារសិទ្ធិមនុស្សអន្តរជាតិកម្ពុជា រហូតដល់បណ្ដេញលោក យ៉ាស្ហហ្កាយ ឱ្យចាកចេញពីប្រទេសកម្ពុជាថែមទៀតផង ។

ការថ្កោលទោស និងការបដិសេធមិនទទួលស្គាល់របស់កម្ពុជាបង្ហាញថា រដ្ឋាភិបាលកម្ពុជាមិនមែនជាអ្នកបានប្រព្រឹត្តអំពើរំលោភបំពានទៅលើសិទ្ធិសេរីភាពមនុស្សដូចរបាយការណ៍នៃលោកទាំងពីរបានរាយការណ៍នោះទេ មានន័យថាគឺសុទ្ធតែនិយាយក្លែងក្លាយបំផ្លើស និយាយដោយសារតែមានគំនុំគំគួនស្អប់រូបលោកនាយករដ្ឋមន្ត្រីកម្ពុជាតែប៉ុណ្ណោះ ។

ប៉ុន្តែមតិអង្គការការពារសិទ្ធិមនុស្សផ្សេងទៀតក្តី អង្គការក្រៅរដ្ឋាភិបាលការពារលទ្ធិ-ប្រជាធិបតេយ្យក្តី សុទ្ធតែបានថ្លែងប្រហាក់ប្រហែលឬដូចគ្នាទៅនឹងរបាយការណ៍របស់លោក យ៉ាស្ហហ្កាយ និងលោក ប្រេដ អាដេម នោះដែរ ។

ដោយហេតុគេមើលឃើញយ៉ាងជាក់ច្បាស់ទៅលើប្រជាពលរដ្ឋខ្មែរ ដែលមន្ត្រីកាន់អំណាចមួយចំនួន និងនាយទុនធំៗមួយចំនួនប្រើអំណាចបំបិទសិទ្ធិសេរីភាព គំរាមកំហែង រំលោភបំពានប្រើហិង្សារហូតដល់មានស្លាប់បាត់បង់ជីវិត គេផ្តល់សិទ្ធិសេរីភាពទៅឱ្យមនុស្សណាដែលនិយាយនិងធ្វើតាមបង្គាប់បញ្ជានៃមេដឹកនាំសំរាប់លើកតំកើងគាំទ្ររដ្ឋាភិបាលតែប៉ុណ្ណោះ ។

តាមការពិតការប្រើសិទ្ធិសេរីភាពមានធំទូលំទូលាយណាស់ មិនមែនដូចការនិយាយអះអាងរបស់រដ្ឋាភិបាលនោះទេ ថាបានផ្តល់ដល់មនុស្សទូទៅអាចប្រកបរបររកស៊ី អាចដើរហើរ អាចរៀបមង្គលការ អាចធ្វើបុណ្យ អាចនិយាយពន្យល់ បង្ហាត់បង្រៀន អាចជ្រើសរើសការងារធ្វើក្នុងរដ្ឋ ឬឯកជនដោយសេរីនោះ មានន័យថារដ្ឋាភិបាលមិនបានផ្តល់សិទ្ធិមនុស្សគ្រប់គ្រាន់នោះទេ ។ សិទ្ធិសេរីភាពដែលមនុស្សគ្រប់មជ្ឈដ្ឋានត្រូវតែបានទទួលពេញលក្ខណៈនោះ គឺសិទ្ធិអំណាចក្នុងសមភាពច្បាប់យុត្តិធម៌សង្គមដូចគ្នា ហើយនិងសិទ្ធិអំណាចក្នុងការចូលរួមដោះស្រាយបញ្ហាប្រទេសជាតិទាំងអស់ មានទាំងធំទាំងតូច ជាពិសេសសិទ្ធិអំណាចសមស្របទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យក្នុងការតាមដានត្រួតពិនិត្យទៅលើទង្វើ និងការប្រព្រឹត្តក្នុងការគ្រប់គ្រងដឹកនាំរបស់រដ្ឋាភិបាល និងមន្ត្រីគ្រប់ជាន់ថ្នាក់ ។

ក្នុងរដ្ឋធម្មនុញ្ញបានចែងរួចហើយ អំពីបេសកកម្ម ភារកិច្ចត្រូវបំពេញចំពោះប្រទេសជាតិ ដែលបានចាត់ទុកថា ជាមន្ត្រីគ្រប់ជាន់ថ្នាក់សំរាប់បំរើភារកិច្ចរបស់រដ្ឋ និងប្រជាពលរដ្ឋ ហើយត្រូវបានទទួលកំរៃប្រាក់ឈ្នួលប្រចាំខែពីរដ្ឋដែលជាកិច្ចការសាធារណៈ ពុំមែនជាថៅកែនាយទុនម្ចាស់កម្មសិទ្ធិនៃក្រុមហ៊ុនសែនធំនៃឯកជនណាមួយនោះទេ មានន័យថា រដ្ឋាភិបាល និងមន្ត្រីអ្នកស៊ីឈ្នួល និងប្រជាពលរដ្ឋត្រូវការគោរពដល់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ ពុំត្រូវប្រើអំណាចរំលោភបំពានតាមតែអំពើនោះទេ។

នៅក្នុងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋនេះ ប្រជាពលរដ្ឋមានសិទ្ធិអំណាចត្រូវតែហ៊ាននិយាយតវ៉ា ទាមទារ ឬចោទប្រកាន់ទៅលើមន្ត្រីណាមួយដែលបានធ្វើ និងប្រព្រឹត្តអំពើទុច្ចរិតពុករលួយខុសឆ្គងយ៉ាងទម្ងន់ត្រូវតែមានទោសដោយដកចេញពីតំណែងទៅតាមផ្លូវច្បាប់ ដែលបានបញ្ញត្តិហាមប្រាម និងកំណត់ទោសជាធរ-មានរួចទៅហើយដែរ ។

ប៉ុន្តែផ្ទុយទៅវិញ រដ្ឋាភិបាលខ្មែរត្រឡប់ជារក្សាការពារទុកមន្ត្រីទុច្ចរិត ពុករលួយទាំងនោះទៅវិញ រួចហើយបានក្លាយទៅជាមានបុណ្យសក្តិ និងលុយកាក់ ទ្រព្យសម្បត្តិ អំណាចកាន់តែខ្ពស់ច្រើនឡើងយ៉ាងមហាសាល រីឯសកម្មជន ឬប្រជាពលរដ្ឋណាដែលបានដឹង និងលើករឿងនេះឡើងទៅប្ដឹងចោទប្រកាន់មន្ត្រីនោះ ត្រឡប់ទៅជាត្រូវរដ្ឋាភិបាលធ្វើបាប គំរាមកំហែងរហូតបញ្ជាឱ្យក្រុមពិសេសអន្ធពាលសាមាន្យទៅលបលួចវាយបាញ់សម្លាប់ចោលតែម្តងទៀតផង ដូចមានភស្តុតាងជាច្រើនបានទុកកន្លងមករួចហើយដែរ ។

បញ្ហាសិទ្ធិសេរីភាពមនុស្សនៅក្នុងប្រទេសយួនវៀតណាម និងនៅក្នុងប្រទេសខ្មែរកម្ពុជា គឺជាបញ្ហាតែមួយដូចគ្នា ពីព្រោះសព្វថ្ងៃនេះយួនវៀតណាមជាប្រធានាធិបតីត្រួតត្រាលើសហព័ន្ធឥណ្ឌូចិន ដោយសម្ងាត់លាក់មុខ ។ នៅយួនវៀតណាម រដ្ឋាភិបាលយួនធ្វើការរំលោភបំពានសិទ្ធិអំណាចជនជាតិយួនដើមកំណើតខ្មែរ ដែលជាអតីតម្ចាស់ទឹកដីកម្ពុជាក្រោម ហើយឥឡូវបានក្លាយទៅជាជនជាតិភាគតិចក្នុងចំណោមជនជាតិភាគតិចទាំង54សាសន៍ ។

ចំណែកនៅខ្មែរកម្ពុជា មានរដ្ឋាភិបាលខ្មែរដើមកំណើតយួនវៀតណាម ធ្វើការរំលោភបំពានទៅលើសិទ្ធិអំណាចរបស់ជាតិសាសន៍ខ្មែរ ដែលជាម្ចាស់ប្រទេសដូចគ្នា ចាប់តាំងពីកងទ័ពយួនវៀតណាមពីរសែននាក់ បានវាយលុកយកជ័យជំនះកាលពីថ្ងៃទី៧ មករា 1979 ហើយបានតែងតាំងរដ្ឋាភិបាលមួយក្លែងបន្លំថា ជាខ្មែរ ដើម្បីបិទបាំងផែនការ មហិច្ឆតារឹបអូសយកខ្មែរកម្ពុជាឱ្យបានជាប្រទេសរណបរបស់យួនវៀតណាម ។ ភស្តុតាងជាក់ស្តែងអ្នកនាំពាក្យក្រសួងការបរទេសយួន ឡេ យុង ក៏បាននិយាយថ្កោលទោសអង្គការការពារសិទ្ធិមនុស្ស (HUMAN RIGHTS WATCH) នៅក្រុងញូវយ៉កថា ធ្វើរបាយការណ៍ក្លែងក្លាយបន្លំគ្មានការពិតទាល់តែសោះ មិនតែប៉ុណ្ណោះ ប្រធានរដ្ឋសភាយួនឈ្មោះ ង្វៀង ភូទ្រឹង ក៏បាននិយាយយោងតាមកាសែត ញ៉ាន យ៉ិន (NHAN DAN) បានចេញបញ្ជាទៅដល់ប្រធានរដ្ឋសភាខ្មែរ ហេង សំរិន ដោយរំលឹកពីការជួបគ្នា នៅក្រុងហាណូយថា ភាគីទាំងពីរត្រូវតែធ្វើយ៉ាងណាការពារកំលាំងអំណាចយួននៅស្រុកខ្មែរ ឱ្យបានកុំឱ្យកំលាំងប្រតិកិរិយាប្រើទឹកដីប្រទេសយើង ដើម្បីប្រឆាំងបំផ្លិចបំផ្លាញសាមគ្គីភាព និងមិត្តភាពឱ្យសោះ ។


លោក ម៉ម យិន

សរុបសេចក្តីទៅវៀតណាមយួន និងកម្ពុជាខ្មែរ មានវប្បធម៌តែមួយជាមួយគ្នាក្នុងការថ្កោលទោស និងចោទប្រកាន់ទៅដល់អង្គការការពារសិទ្ធិមនុស្សទាំងអស់ ដែលចេញមកពីអង្គការអន្តរជាតិក្តី ពីអង្គការសហប្រជាជាតិក្តី និងពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិក្តី សុទ្ធតែត្រូវបានរដ្ឋាភិបាលយួនវៀតណាម និងខ្មែរកម្ពុជាចាត់ទុកថា ជាអំពើអយុត្តិធម៌ក្លែងក្លាយបន្លំគ្មានមូលដ្ឋានចេញពីយួនវៀតណាម និងខ្មែរកម្ពុជា ជាដាច់ខាតដរាបណាអង្គការនេះពុំព្រមសម្របសម្រួលទៅតាមចេតនានយោបាយដ៏អាក្រក់ និងព្រៃផ្សៃនៃប្រទេសកម្ពុជា និងវៀតណាមនេះទេ ៕


# ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

## Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**

- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ត្លាំង ឆារសាច់គោ
- មីកន្ត្លាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**

- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# អូបាម៉ា ចុះហត្ថលេខាលើច្បាប់ "ស្ទីមឡឹស" "STIMULUS"

**ខ្មែរប៉ុស្តិ៍ : ពិន សំខុន**

ច្បាប់ថ្មីដែល បារ៉ាក់ អូបាម៉ា ប្រធានាធិបតីនៃសហរដ្ឋអាមេរិក បានចុះហត្ថលេខាឱ្យប្រើរួចហើយនោះ បានផ្តល់ដង្ហើម និងបេះដូងថ្មីដល់សេដ្ឋកិច្ច និងសង្គមកិច្ចអាមេរិកាំង ឱ្យមានសន្ទុះថាមពលខ្ពស់ឡើងវិញ ។ ប្រជាពលរដ្ឋអាមេរិកាំង បានទទួលយកសេចក្តីសម្រេចចិត្តដ៏ក្លាហានដំបូងបង្អស់របស់ប្រធានាធិបតីយ៉ាងរីករាយសប្បាយចិត្ត ។



ពលរដ្ឋខ្មែរ-អាមេរិកាំង ក៏នៅក្នុងស្ថានភាពរង់ចាំទទួលផលពីការចុះហត្ថលេខាដ៏ចំបងនេះដែរ ។ តើច្បាប់នោះនឹងផ្តល់អ្វីខ្លះដល់ពលរដ្ឋអាមេរិកាំង ?

ច្បាប់ " ស្ទីមឡឹស " នោះនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលចាយថវិកាចំនួន ៧៨៧ពាន់លានដុល្លារ ដើម្បីបន្ថយប្រាក់ចំណាយរបស់ពលរដ្ឋទៅលើការបង់តាក់, ធ្វើឱ្យតម្លៃទិញ "ការធានាសុខភាព", ធ្វើផ្លូវ ឬជួសជុលផ្លូវឱ្យពលរដ្ឋប្រើប្រាស់, ថែរក្សាឱ្យគ្រូល្អៗ នៅបង្រៀនកូនចៅ ... ។ល។

ថ្ងៃអាទិត្យ ទី២២ កុម្ភៈ កន្លងទៅនេះ នៅផ្លូវលេខ៧ខាងត្បូងហ្វីឡាដែលហ្វីយ៉ា ពាណិជ្ជករជាច្រើនបានរអ៊ូរថា " អតិថិជនឥឡូវមិនសូវមកទិញ ខ្ញុំលក់មិនដាច់សោះ ! "រីឯអ្នកផ្សេងទៀតដើរលើចិញ្ចើមថ្នល់វិញ ក៏និយាយថា " ខ្មែរយើងឥឡូវនេះ បាត់ការងារយ៉ាងហោចណាស់ក៏៥០% ដែរ ខ្ញុំរកលុយមិនបានទេ ព្រោះគ្មានការងារធ្វើ " ។ អ្នកទាំងនោះក៏រង់ចាំបាតុភូតល្អៗ ដែលចេញពីឥទ្ធិពលថវិកា ៧៨៧ពាន់លានដុល្លារនោះដែរ ។ ដូច្នេះ តើលុយនោះនឹងទៅជួយវិស័យណាខ្លះ ? ដោយវិធីណា ?

**~ ផ្នែកពន្ធដារ :**

សម្រាលពន្ធដារដល់គ្រួសារដែលមានកូនរៀននៅមហាវិទ្យាល័យ, ដល់ការទិញរថយន្តថ្មី, ដល់អ្នកដែលទិញផ្ទះជាលើកដំបូង ឬជួសជុលផ្ទះខ្លួនឯងដែលប្រើថាមពលច្រើន ។

អ្នកធ្វើការនឹងទទួលសំណងពីក្រសួងពន្ធដារចំនួន ៤០០ដុល្លារ ( អ្នកនៅលីវ ) និង ៨០០ដុល្លារ សំរាប់អ្នកមានគ្រួសារ ប្រាក់នោះនឹងមកដល់នៅម្តុំខែមិថុនា (June).

អ្នកមានកូននៅក្នុងបន្ទុក មានប្រាក់ចំណូលតិច នឹងទទួលបាន " តាក់ក្រេឌីត " ចំនួន ១០០០ ដុល្លារ សំរាប់ចំណាយលើប្រាក់ពន្ធដារ បើមានកូនចាប់ពីបីនាក់ឡើងទៅនឹងទទួលបានចំណូលពី "តាក់ក្រេឌីត "រឹតតែច្រើនទៀត ។

សំរាប់អ្នកទិញផ្ទះលើកដំបូង បើទិញនៅមុនថ្ងៃទី១ ធ្នូ ឆ្នាំ២០០៩ នឹងទទួលបាន "តាក់ក្រេឌីត" ចំនួន៨០០០ដុល្លារ, បើទិញឡានថ្មីវិញ គឺទិញដោយមិនបាច់បង់តាក់ ។



រីឯអ្នកដែលជាម្ចាស់ផ្ទះរួចហើយ តែចង់ជួសជុលផ្ទះ ដើម្បីសន្សំថាមពលអាចនឹងរដ្ឋជួយដល់ទៅ ៣០% កុំឱ្យលើសពី ១៥០០ដុល្លារ. អាចជួយចេញថ្លៃបង់សាលាកូន ដែលរៀននៅមហាវិទ្យាល័យ រហូតដល់ទៅ២៥០០ដុល្លារ ។

**~ ធានារ៉ាប់រងសុខភាព :**

អ្នកធ្វើការណាដែលបាត់បង់ការងារ ហើយឥតមាន " ធានារ៉ាប់រងសុខភាព " គេអាចរកទិញវិញបានក្នុងតម្លៃយ៉ាងថោកបំផុត ។

ដើម្បីជួយពលរដ្ឋឱ្យមាន "ការធានាសុខភាព" រដ្ឋនឹងជួយលើការចំណាយសុខភាព ៦៥% ឯម្ចាស់ខ្លួនចេញតែ៣៥% តែប៉ុណ្ណោះ អ្នកបាត់បង់ការងារគេគិតឱ្យបានចំពោះអ្នកបាត់បង់ការងារតាំងពីខែកញ្ញា ឆ្នាំ២០០៨ រហូតដល់ចុងឆ្នាំ២០០៩ នៅលើជំនួយទាំងនោះ មានថវិកា ៨៧ពាន់លាន សំរាប់ជួយខាងផ្នែកថ្នាំពេទ្យផង ។

**~ សិក្សាធិការ :**

គោលដៅធំសំរាប់សិក្សាធិការ គឺទប់ស្កាត់កុំឱ្យមានការបន្ថយចំនួនគ្រូបង្រៀន ( គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សា ចំនួន ៦០ម៉ឺននាក់ នឹងត្រូវដកចេញ **(តនៅទំព័រទី១៧)**



## ការិយាល័យមេធាវី លិនហ្សេ ដ័រឆ

## LAW OFFICE OF LINDSAY DOERING

**ទទួលការពារផលប្រយោជន៍លោកអ្នកករណី នូវនៅតាមផ្លូវច្បាប់ដូចជា :**

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



**ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**

General practice law office handling matters in :

Corporations and business Transations
Read Estate
Car Accidents
Work Place Injury
Immigration
Criminal Defense

Experienced, professional service and reasonable rate. Interpreter available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com

## ឱសថស្ថាន ផ្លូវលេខ 8

## វេជ្ជបណ្ឌិត អាឡិច លឿង

## 8th Street Pharmacy

Alex. N. Luong, RPh.

OPEN HOURS:
Mon. – Fri.: 9:00AM – 7:00PM
Sat.: 9:00AM – 5:00PM
Sun.: 9:00AM – 3:00PM

បើចង់បានសេវាថ្នាំពេទ្យឆាប់ សូមអញ្ជើញមករកអ្នកភូមិរបស់អ្នក គឺឱសថស្ថាន ផ្លូវលេខ ៨ ( ជ្រុងផ្លូវលេខ៨ និង CHRISTIAN ហ្វីឡា- ខាងត្បូង)



☛ យើងទទួលប័ណ្ណមេឌីបែរ នឹងមេឌីខេត
▸ **We Do accept Medicare & Medicaid**
▸ **We Do Offer Alternative Natural Medicines Including:**
☛ យើងមានផ្តល់ជូននូវឱសថធម្មជាតិ មានដូចជា :

- Prostate -7 – ជួយដល់សុខភាព "ប្រស្តេដ" ដលបុរស
- Pure Fresh Royal Jelly – ជួយលើកដំកើងនូវរសជាតិនៃជីវិត
- Fe-mon-9 – ជួយដល់ស្ត្រីនៅពេលមានអ័រម៉ូន
- Super Cross – ជួយបន្ថយការតាំងបេះដូង,ការលើសឈាម ឬកូឡេស្តេរ៉ូលច្រើន
- Gold Medal Swiss Placenta "សុកពពែស្វីស" មេដាយមាស សំរាប់កែសម្ផស្ស

819 S. 8th St. Philadelphia, Pa 19147
Phone: 215-592-8888 Fax: 215-592-9888

អត្ថបទ
មនោសញ្ចេតនា

# ក្តីស្នេហ៍គ្មានទីបញ្ចប់

**ខ្មែរប៉ុស្តិ៍ : គឹម ភឿន**

•••ខ្ញុំមិនអាចបំភ្លេចបានសោះ ទោះរឿងរ៉ាវបានកន្លងទៅយូរណាស់ហើយ ។ កាលនោះជាពេលចាប់ផ្តើមវិស្សមកាលឆ្នាំ១៩៧០ ខ្ញុំបានចេញពីមហាវិទ្យាល័យកសិកម្ម នាងវិញក៏ចេញពីមហាវិទ្យាល័យគរុកោសល្យ ហើយក៏បានស្ម័គ្រចិត្តចេញទៅបង្រៀននៅវិទ្យាល័យអង្គតាសោម នៃខេត្តតាកែវ ។ ឪពុកនាងជានាយទាហានជាន់ខ្ពស់ម្នាក់ ឯម្តាយជាអ្នកជំនួញអចលនៈវត្ថុម្នាក់ មានទ្រព្យស្តុកស្តម្ភណាស់ ។ អ្នកទាំងពីរមិនមានបំណងឱ្យកូនរបស់គាត់ចេញធ្វើជាសាស្ត្រាចារ្យ ដើម្បីបានប្រាក់ខែបន្តិចបន្តួចចិញ្ចឹមជីវិតយ៉ាងនេះសោះឡើយ ។ ប៉ុន្តែនាងស្រឡាញ់របរនេះ នាងចង់ដឹកនាំក្មេងៗ ឱ្យមានគំនិតចេះស្រឡាញ់ជាតិមាតុភូមិរបស់ខ្លួន ព្រោះនាងសង្កេតឃើញថា កម្មវិធីសិក្សាស្រុកខ្មែរ មិនបានយកចិត្តទុកដាក់លើបញ្ហានេះ ។ តាំងពីដើមរៀងមកកម្មវិធីសិក្សារបស់យើងហាក់ដូចជាមានគោលបំណងតែបណ្តុះបណ្តាលឱ្យសិស្សរៀនចេះចប់ ក៏ខិតខំប្រឡងឱ្យបានមុខងារមួយក្នុងសង្គម ខំធ្វើម៉េចឱ្យមានមុខមាត់កាន់តែធំ សល់លុយកាក់កាន់តែច្រើន ហើយចង់ធ្វើអ្វីក៏បាន ។ នេះគោលបំណងធំបំផុតនៃកម្មវិធីសិក្សាខ្មែរយើងតាំងពីមុនរៀងមក ។

ភ្នំពេញ ខែមិថុនា ឆ្នាំនោះ ក្រហមច្រាលទៅដោយផ្កាក្ងោករីកស្គុះស្គាយ ។ រដូវផ្កាក្ងោករីករួចរោយទៅតាមដងវិថីនានា ជាសញ្ញាប្រាប់ថា វិស្សមកាលចូលមក សិស្សនិស្សិតត្រូវបែកគ្នាបីខែត្រឡប់ទៅផ្ទះសំបែងជួបជុំម្តាយឪពុក និងពិសេសឆ្នាំនេះ មិនត្រឹមតែត្រឡប់ទៅជួបឪពុកម្តាយរៀងខ្លួនដូចធម្មតានោះទេ តែទៅជួបគាត់ដោយព្រួយបារម្ភ និងសង្គ្រាមចាប់ផ្តើមឆេះឡើង ។ តើអនាគតរបស់ខ្លួននឹងក្លាយទៅជាយ៉ាងណាចំពោះសង្គ្រាមកំពុងតែចាប់ផ្តើមឆាប់ឆេះនេះ ? ។

សិស្សនិស្សិតខ្លះមិនព្រមត្រឡប់ទៅស្រុកភូមិរបស់ខ្លួនទេ តែនៅរង់ចាំចុះឈ្មោះចូលកងទ័ពសាធារណរដ្ឋ ដែលលោកសេនាប្រមុខ លន់ នល់ ស្រែកអំពាវនាវឱ្យចូលតស៊ូវាយបណ្តេញកងទ័ពឈ្លានពានយួនកុម្មុយនិស្ត ឯសិស្សនិស្សិតដែលនៅស្រុកភូមិរបស់ខ្លួន ក៏ស្តាប់ការអំពាវនាវរបស់សម្តេចឪ ចូលព្រៃមាគីយ៍ដែរ ។ សង្គ្រាមរវាងឈាមឯងចាប់ផ្តើមផ្ទុះឆេះឡើងហើយ គួរ



ឱ្យរន្ធត់តក់ស្លុតខ្លាំងណាស់ ។

ខ្ញុំកំពុងរារែកនៅចំពោះបញ្ហារាប់មិនអស់ក្តីស្នេហ៍មួយដែលបានចាប់ពន្លកយូរឆ្នាំមកហើយ តាំងតែពីស្គាល់គ្នា ក្រោមដំបូលវិទ្យាល័យព្រះ-ស៊ីសុវត្ថិជាមួយគ្នា ។ រួចហើយខ្ញុំបែកទៅបន្តការសិក្សានៅមហាវិទ្យាល័យកសិកម្ម ។ ក្រោយមកនាងក៏ចេញទៅសិក្សាមហាវិទ្យាល័យគរុកោសល្យ ដែលខុសពីគោលបំណងរបស់អ្នកមានគុណទាំងពីររបស់ខ្លួន ។ គាត់ចង់ឱ្យកូនទៅបន្តការសិក្សានៅបរទេស ប្រទេសបារាំងទៀតនៅឧត្តមសិក្សា ។ គោលបំណងរបស់លោកទាំងពីរពុំបានសម្រេចនេះ ក៏ដោយសារមួយភាគធំពីការដែលនាងបានចាប់ចិត្តស្រឡាញ់នូវស្នេហាដំបូង ។

បុប្ផាអូនអើយបងចំបែង
ទុក្ខព្រួយខ្លួនឯងបងទ្រាំបាន
តែទុក្ខប្រាណអូនទាំងប៉ុន្មាន
ធ្វើម្តេចដោះបានទៅស្រី ។
វាសនានៃយើងទាំងពីរប្រាណ
លោកនាំឱ្យបានស្រឡាញ់គ្នា
តែតទៅមុខប្រែយ៉ាងណា
ឱះឱវាសនាយើងទាំងពីរទ្វេ ។
បងដឹងថាបងអ្នកឱបផ្កាយ
ទុក្ខធំនឹងក្លាយជាសាគរ
ហេតុអីក៏ផ្កាយបានធ្លាក់មក
អភ័ព្វណាស់ទំ ! មាសកល្យាណ ។
បងអាណិតអូនស្ងួតពន្លក
នាងបានកើតមកក្នុងសុខា
ពីនេះទៅមុខអូនយ៉ាងណា ?
នេះគឺវាសនានឹងតាក់តែង ។

កំពុងតែធ្លាក់ចុះក្នុងអារម្មណ៍ទុក្ខព្រួយអស់សង្ឃឹមអណ្តែតអណ្តូង ស្រាប់តែបុប្ផាបានទាញអារម្មណ៍ខ្ញុំមករកបច្ចុប្បន្ន :

-បងវិរៈ បងកំពុងគិតអីហ្នឹង ?

ខ្ញុំភ្ញាក់មកកាន់បច្ចុប្បន្នហើយ តែមួយសន្ទុះក្រោយមកទើបតបឆ្លើយ :

យើងបានចេញពីសាលាទាំងអស់គ្នា តែយើងក៏មិនដឹងថាអនាគតយើងបែរជាយ៉ាងណា...ម្នាក់ៗត្រូវទៅបំពេញការងាររៀងៗខ្លួន ។ យើងត្រូវបែកឆ្ងាយពីគ្នា...ដោយមិនទាន់បានរៀបការ ។ ចុះម៉េចបងមិនព្រមគិតគូររឿងនេះឱ្យបានឆាប់ទៅ ? យើងបានស្រឡាញ់គ្នាអស់រយៈពេលបួនឆ្នាំហើយ ។ អូនចេះតែនៅរង់ចាំបង ។

ខ្ញុំចាប់ស្ទាបដៃនាងដោយថ្នមៗ

-បុប្ផា ! បងអរគុណអស់មួយជីវិត ចំពោះក្តីអាណិត ស្រឡាញ់របស់អូនមកលើរូបបង ។ អូនបានលះបង់ច្រើនណាស់មកលើរូបបងជាក្មេងកំព្រា ។ គ្មានម៉ែគ្មានឪជាទីពឹង ។ រៀនដល់បានចេញពីសាលា ដោយសារព្រះសង្ឃ ដោយសារខំព្យាយាមខ្លួនឯង ដោយសារអាហារូបករណ៍ដែលបងទទួលបាន ។ ឥឡូវបានចេញពីសាលាជាមួយសញ្ញាប័ត្រមួយសន្លឹក តែបាតដៃទទេ បងធ្វើអីក៏មិនកើត ហើយក៏សូមអង្វរអូនឱ្យរង់ចាំ...។ បងដូចជាមនុស្សរើសបានមាស តែរកក្រដាសខ្ចប់មិនបាន ខ្លាចតែមាសមិននៅគង់វង់តទៅទៀតបាន បងសុំសារភាពថា បើបាត់មាសមួយដុំនេះទៅ គឺបងមានទុក្ខធំណាស់ តែកំហុសមកតែពីបងអសកម្មភាព និងគ្មានមធ្យោ-បាយថែរក្សា ។ បើអូនបែកពីបងទៅ មិនមែនកំហុសរបស់អូនទេ តែជាកំហុសរបស់បង បងគ្មានបន្ទោសអូនទេ បងខឹងតែចំពោះវាសនាបង ខឹងនឹងខ្លួនបងតែប៉ុណ្ណោះ ។

ឱដួងតារាដ៏សែនខ្ពស់
បន្ទាបចុះមកដល់ទ្រូងខ្ញុំ
ព្រមទាំងវាចារអង្វរសុំ
ឱ្យខ្ញុំខិតខំរក្សាថៃ ។
អូនបានលះបង់គ្រប់ជំហ៊ាន
ឈានចាកវិមានឋានសួគ៌នាយ
មកបំភ្លឺស្ថានដ៏សែនឆ្ងាយ
បងខ្លាចតែផ្កាយអ័ព្ទរស្មី ។
ខ្លាចរស់មិនសម ថ្នមមិនគាប់
ព្រោះបងអភ័ព្វពេកកន្លង
បេះបានបុប្ផាពីរបង
តែខ្លួនខ្ញុំរងឈ្នះវេរា ?
បើថ្ងៃណាមួយអូនបែកទៅ
បងរងទុក្ខនៅឯកា
កំហុសព្រោះបងទេជីវ៉ា
បងស៊ូខ្លោចផ្សារតែម្នាក់ឯង ។

ដោយខំរកពាក្យនិយាយអីតទៅទៀតពុំចេញ សុខចិត្តដកដង្ហើមវែង ។ បុប្ផាក៏បន្លឺវាចារដោយមានលាយឡំភាពទុក្ខព្រួយ :

-ចេញពីសាលាហើយ បងគិតធ្វើអីទៀត ?

-ក្រសួងកសិកម្ម មិនទាន់មានគម្រោងរើសបុគ្គលិកថ្មីទេ មានតែខាងកងទ័ព គេកំពុងត្រូវការរើសអ្នកស្ម័គ្រចិត្តចូលបំរើកងទ័ព ។ ពួកនិស្សិតគេនឹងបញ្ជូនទៅរៀនស្រុកយួននៅមជ្ឈមណ្ឌលនានា ដើម្បីក្លាយទៅជានាយទាហានមកវិញជួយវាយរំដោះទឹកដី ដែលខ្មាំងកំពុងចូលមករុនរាន ។

ខ្ញុំដឹងចិត្តនាងថា នាងមិនពេញចិត្តនឹងមុខរបររបស់ប្តីនាងជាអ្នកលក់ជីវិតយ៉ាងនោះទេ ។ អនាគតទៅជាយ៉ាងម៉េចទៅ ? ម៉េចមិនធ្វើអីផ្សេង ចាំទៅលក់ជីវិតយ៉ាងនេះ ។

នាងដកដង្ហើមវែងមិនស្តីទុកឱ្យអារម្មណ៍អណ្តែតអណ្តូងទៅដល់អនន្តកាល ។

ដើម្បីឱ្យអារម្មណ៍ដ៏សែនធ្ងន់នេះ បានឆាប់រសាយទៅ ខ្ញុំបានទាញដៃនាងស្រាលៗ ឱ្យក្រោកចេញពីបង់ថ្ម ក្រោមដើមក្ងោកនៃសួនច្បារវិមានឯករាជ្យ ហើយបោះជំហ៊ានមួយៗ ស្ទាប៉ះនឹងស្មៅនៅក្រោមស្បៃរាត្រីដើមរនោច ។

យូរណាស់ទើបនាងបន្លឺឡើងយ៉ាងអួលអាក់ : ស្រេចតែបងសម្រេចចិត្តចុះ បុប្ផាមិនជំទាស់អីទេ បើវាសនាយើងល្អ យើងមុខជាមិនបែកគ្នាទេ ។

(នៅមានត)




# ខ្មែរជួសជុលរថយន្ត

KHMER AUTO REPAIR

CAR INSPECTION, DIAGNOSTIC & REPAIR

ត្រួតពិនិត្យរថយន្តតាមកុំព្យូទ័រ
•[illegible]
•ហ្វ្រាំង ឬ ប្រេក
•[illegible]
•[illegible]
•[illegible]
•[illegible]
•[illegible]

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace.

5302 Rising Sun Avenue. Philadelphia, Pa 19120
215-939-5436

ទំព័រវិថី បំភ្លឺជីវិត

# នរក និងឋានសួគ៌នៅជិតគ្នាបង្កើយ

**ដោយ : អ៊ឹម លឿម**

•ក្ដីសុខ និងក្ដីទុក្ខ ត្រូវបានគេបែងចែកថា មានលក្ខណៈផ្ទុយពីគ្នាយ៉ាងដាច់ស្រឡះ ប៉ុន្តែវត្ថុទាំងពីរនេះ ក៏នៅកៀកក្បែរគ្នាជិតបំផុតផងដែរ ។

អ្នកចិត្តសាស្ត្របានធ្វើការប្រៀបធៀបចំពោះពាក្យថា " នរក និងឋានសួគ៌ " ទៅនឹងការសម្លឹងមើលទឹកនៅក្នុងកែវដ៏សែនថ្លាមួយ ។ បើសិនជាយើងសម្លឹងមើលកែវ ដែលមានទឹកពេញ និងកែវមួយទៀត ដែលមានទឹកតែបន្តិច នោះឃើញថា វាមានលក្ខណៈខុសគ្នាយ៉ាងដាច់ស្រឡះ ។

យ៉ាងណាមិញ ចំពោះជីវិតដល់សុខក្សេមក្សាន្ត និងទុក្ខសោកយ៉ាងណានោះ គឺស្ថិតនៅត្រង់ការចេះ " ពិចារណា " ហើយត្រូវសម្លឹងមើលកែវដែលមានទឹកពេញ ពោល គឺមិនត្រូវសម្លឹងមើលកែវដែលគ្មានទឹកមួយតំណក់នោះឡើយ ។ ការដែលមនុស្សយើងតែងតែជួបប្រទះតែភាពទុក្ខសោកជាប្រចាំនោះ ពីព្រោះដោយសារតែអ្នកទាំងនោះ រវល់តែជាប់ជំពាក់ចំពោះគំនិតអគតិនានា ដែលវាជាគំនិតមិនបង្កើតនូវឋានសួគ៌ដ៏ត្រឹមត្រូវមួយ ។

ពេលខ្លះ ដោយគ្រាន់តែយើងផ្លាស់ប្ដូរនូវគំនិត និងទស្សនៈគតិជាថ្មី ដោយសារការសម្លឹងមើលពិភពលោកខាងក្រៅក្នុងផ្លូវដ៏ត្រឹមត្រូវ និងប្រណិប័ត្រនូវទង្វើល្អៗ នោះក៏អាចនាំខ្លួនយើងឱ្យមានក្ដីសុខក្សេមក្សាន្តដល់ជីវិតបាន ។ ៤ ចំណុចខាងក្រោមជាគន្លឹះដ៏មានសារៈប្រយោជន៍ ដែលយើងគួរយល់ដឹង :

១- ត្រូវមើលមិត្តភ័ក្ររបស់យើងទាំងអស់ថាពួកគេម្នាក់ៗ សុទ្ធសឹងតែមានចំណុចល្អៗ គ្រប់គ្នា ហើយពុំមាននរណាម្នាក់នៅក្នុងលោកនេះដែលល្អឥតខ្ចោះនោះឡើយ ឬក៏មានតែចំណុចមិនល្អសោះនោះឡើយដែរ ។ គ្រប់ៗរូបរមែងតែងតែមានចំណុចល្អ និងចំណុចអាក្រក់នៅលាយឡំជាមួយគ្នាជានិច្ច ។

២- ត្រូវគិតដល់អំពើល្អ ដែលអ្នកដទៃបានធ្វើល្អចំពោះយើង និងត្រូវនឹកឃើញនូវអំពើល្អនានា ដែលយើងធ្លាប់បានធ្វើចំពោះគ្នាទៅវិញទៅមក ។

៣- ឃ្លាំមើលចំពោះមិត្តភ័ក្រដោយការយោគយល់ និងការយល់ចិត្តយល់ថ្លើមគ្នា ។

៤- សម្លឹងមើលមិត្តភ័ក្រដោយក្ដីមេត្តា ត្រូវធ្វើចិត្តគំនិតឱ្យសុភាពរាបសារ និងមើលមិត្តភ័ក្រដោយក្ដីសទ្ធា ព្រមទាំងមានជំនឿថា នៅថ្ងៃណាមួយពួកគេ ( មិត្តភ័ក្រ ) និងមានភាពល្អប្រសើរជាងពេលនេះ ។

ការហ្វឹកហាត់ធ្វើចិត្តគំនិត ក្នុងការគិតគូរបែបនេះ ពិតជានាំអារម្មណ៍របស់យើងឱ្យមាននូវថាមពលខាងផ្លូវចិត្ត និងខាងកម្លាំងកាយកាន់តែខ្លាំងឡើងៗ ហើយថែមទាំងធ្វើឱ្យជីវិតយើងឱ្យមានក្ដីសុខក្សេមក្សាន្តកាន់តែទ្វេឡើង ។

"សត្វចាបដែលហើរទៅហើយ វាពុំបានបន្សល់ទុកនូវស្នាមដានជើងរបស់វានៅលើលំហរវេហាស៍ឡើយ រីឯបុគ្គលដែលបានធ្វើអំពើល្អពិតៗ ក៏ពុំបាននឹកគិតអំពីគុណសម្បត្តិរបស់ខ្លួនចំពោះអ្នកដទៃឡើយដែរ " ៕


New World Travel II
ញូវលត្រាវែលធូ
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ-សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036



គណបក្សសិទ្ធិមនុស្ស
បំរើ-ការពារ-កសាង
HUMAN RIGTHS PARTY





ដឹកនាំដោយឯកឧត្តម កឹម សុខា
សូមអញ្ជើញលោក.លោកស្រីមើលក្នុងគេហទំព័រ WWW.HRPCambodia.info ដើម្បីស្ដាប់វិទ្យុ និងតាមដានព័ត៌មានទាន់សភាពការណ៍ទាក់ទងនឹងប្រទេសកម្ពុជា ។
បើអស់លោកចង់ចូលរួម សូមទាក់ទងមក
លោក ញ៉ាយ ចំរើន ទូរស័ព្ទ :
267-226-7861 អ៊ីម៉ែល : chamroeunkh@yahoo.com



Washington Wellness Care








•បើលោកអ្នកមានគ្រោះថ្នាក់រថយន្ត,មានរបួសនៅកន្លែងធ្វើការ ឬក៏រអិល ហើយដួលរហូតដល់មានរបួសតែពុំដឹងនរណាជាអ្នកទទួលខុសត្រូវ ?
•យើងអាចជួយលោកអ្នកបាន
•មជ្ឈមណ្ឌល "វ៉ាស៊ីនតុនវែលណេសឃែ" មានបទពិសោធន៍ក្នុងរឿងរបួសក្នុងគ្រោះថ្នាក់រថយន្ត មានរបួសនៅកន្លែងធ្វើការនឹងរអិលដួលបណ្ដាលឱ្យរបួស
•យើងណែនាំទៅមេធាវីដែលអាចការពារសិទ្ធិលោកអ្នកបាននៅពេលមានគ្រោះថ្នាក់
•អាចផ្ដល់ផែនការណ៍ជួយចេញសោហ៊ុយចំពោះបុគ្គលដែលគ្មានប័ណ្ណធានារ៉ាប់រង
•សូមទូរស័ព្ទមក "វ៉ាស៊ិនតុនវែលខែល" ភ្លាម ដើម្បីឱ្យដឹងថា តើយើងអាចជួយលោកអ្នកដោយវិធីណា
រីតី និយាយភាសាខ្មែរ លេខទូរស័ព្ទ : 215-380-1350
• If you got into a car accident, fell injury at work, or slip & fall injured but not sure who you can turn to?
• WE CAN HELP.
• The Washington Wellness Care Center is specialized in treating auto accident injuries, work related injuries, and slip andfall injuries.
• We also can refer you attorneys who can provide what your
• rights are when you got into the accident.
• Low payment plan available for individuals without insurance.
500 Washington Ave., 1st Fl. Philadelphia, Pa 19147 Phone: 215-551-6838

(តមកពីទំព័រទី០១)

# អតីតអគ្គមេបញ្ជាការកងទ័ព...

ដើម្បីទ្រទ្រង់សភាពការណ៍សន្តិសុខជាតិ ពីព្រោះទំនាស់រវាង ហ៊ុន សែន និង ជា ស៊ីម អាចចែកបក្សគ្នាជាពីរក៏ថាបាន ។

បន្ទាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាឱ្យតុលាកាស៊ើបអង្កេតករណីលោកអតីតអគ្គមេ-បញ្ជាការ កែ គីមយ៉ាន ថា អាចពាក់ព័ន្ធនឹងការរកស៊ីដីធ្លីជាច្រើនកន្លែង ព្រមទាំងព្រទ្យសម្បត្តិផ្ទាល់ខ្លួនរួចមក ក៏បានបង្កឱ្យមានរឿងអាស្រូវជាច្រើនបានផ្ទុះឡើងគួរឱ្យបារម្ភសំរាប់លោកនាយឧត្តមសេនីយ៍រូបនេះ ។

តាមរយៈការថ្លែងរបស់ ហ៊ុន សែន និងបក្ខពួករបស់លោកបាននិយាយប្រហាក់ប្រហែលគ្នាថា ការដកលោកអតីតអគ្គមេបញ្ជាការរូបនេះគឺជាកំណែទំរង់កងទ័ពឱ្យស្របតាមស្តង់ដា គឺវាមិនមែនជាការឈ្លោះប្រកែកគ្នាដូចពាក្យចចាមអារ៉ាមនោះទេ ។

ប៉ុន្តែក្រោយមក ហ៊ុន សែន ក៏និយាយសំរួលស្ថានការណ៍ថា រឿងដកតំណែង កែ គីមយ៉ាន វាជារឿងធ្ងន់ធ្ងរក្នុងការរកស៊ីដីធ្លីទៅវិញ ។ ការអះអាងរបស់ ហ៊ុន សែន វាស្របនឹងកំណត់ហេតុរបស់អង្គប្រជុំរបស់មន្ត្រីគណបក្សប្រជាជនកម្ពុជាដែលបញ្ជាក់ថា ក្រសួងដែនដីនគរូបនីយកម្ម ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងរាជរដ្ឋាភិបាល ដែលពាក់ព័ន្ធត្រូវធ្វើការស៊ើបអង្កេតករណីរឿង កែ គីមយ៉ាន ឱ្យបានហ្មត់ចត់ ។

តាមរយៈឯកសារដែលក្រុមអ្នកសារព័ត៌មានទទួលបាននោះវាឆ្លុះបញ្ចាំងឱ្យឃើញពីការដកអតីតអគ្គមេបញ្ជាការ កែ គីមយ៉ាន ពុំមែនជារឿងកំណែទំរង់កងទ័ពនោះទេ តែជារឿងដីធ្លីទៅវិញ ។ ដូច្នេះវាជារឿងទំនាស់ផលប្រយោជន៍រវាងលោក កែ គីមយ៉ាន និងក្រុមលោក ហ៊ុន សែន ទៅវិញ ។

យោងតាមសេចក្តីថ្លែងការណ៍របស់ទីស្តីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី១៥ ខែកុម្ភៈ មិនបានបដិសេធចំពោះកំណត់ហេតុនៃអង្គប្រជុំរបស់ដោយរដ្ឋាភិបាលនោះទេ ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីដែលត្រូវ The Cambodia Daily ស្រង់សំដីនោះឱ្យបានដឹងថា ភាពមិនស្របច្បាប់នៃឯកសារនេះ គឺត្រូវបានធ្លាយដល់ដៃសាធារណ-ជន ពីព្រោះវាជាទ្រព្យសម្បត្តិរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ ។ ការផ្សព្វផ្សាយព័ត៌មានបែបនេះវាធ្វើឱ្យប៉ះពាល់សន្តិសុខរបស់រាជរដ្ឋាភិបាលទៀតផង ។

លោក ផៃ ស៊ីផាន បន្តថា វាប៉ះពាល់ដល់សន្តិសុខជាតិ មានកាសែតខ្លះបានប្រើឯកសារនេះ ដើម្បីអះអាងថា មានជំលោះកើតឡើងរវាងលោក ជា ស៊ីម ប្រធានគណបក្សប្រជាជននិងនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាពិសេស គឺធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់លោក កែ គីមយ៉ាន ដែលលោកនៅមិនទាន់កាត់ទោសនៅឡើយ ។

ទាក់ទិនទៅនឹងការប៉ះពាល់ដល់សន្តិសុខជាតិនេះ លោក លីវ សុវណ្ណា មេធាវីកាត់ក្តី បានបញ្ជាក់ថា រឿងនេះវាមិនប៉ះពាល់ដល់សន្តិសុខជាតិទេ ពីព្រោះរឿងមានតែមនុស្សម្នាក់ ហើយបុគ្គលនោះឈប់ដឹកនាំកំលាំងយោធាទៅហើយ ។

ពាក្យចចាមអារ៉ាមជាច្រើនបានផ្ទុះឡើងជាបន្តបន្ទាប់ ធ្វើឱ្យប្រជាជនមានចម្ងល់ពីសុវត្ថិភាពរបស់អតីតអគ្គមេបញ្ជាការកងទ័ពរូបនេះយ៉ាងខ្លាំង ដោយប្រភពខ្លះបានអះអាងថា កែ គីមយ៉ាន ត្រូវបានគេចាប់ដាក់មន្ទីរឃុំឃាំងក្នុងទីបញ្ជាការកងរាជអាវុធហត្ថ ដើម្បីស្វែងយុត្តិធម៌ ករណីជុំវិញជំលោះដីធ្លីនេះឱ្យប្រសើរឡើង ។ បើសិនជាទុកឱ្យគាត់នៅក្រៅមន្ទីរឃុំឃាំងតុលាការនៅតែខ្លាចឥទ្ធិពលរបស់គាត់ គឺមិនថាអ្នកស្រុកដែលរងគ្រោះក៏មិនអាចទទួលបានយុត្តិធម៌ទេ ។

ប្រភពខ្លះទៀតបញ្ជាក់ថា ពេលនេះ កែ គីមយ៉ាន មិនដឹងជាលាក់ខ្លួននៅកន្លែងណាទេ ហើយទំនងជាចេញទៅក្រៅប្រទេស ចាប់តាំងពីគាត់ចូលរួមប្រគល់តំណែងឱ្យលោក ប៉ុល សារឿន ជាអគ្គមេបញ្ជាការមកម្ល៉េះ ។ ចំណែកឯនៅគេហដ្ឋានរបស់លោកស្ថិតក្នុងសភាពស្ងប់ស្ងាត់ គ្មានទាហានយាមកាមដូចមុននោះទេ ។

ពាក្យចចាមអារ៉ាមទាំងនេះត្រូវបានលោក ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី និងជាអគ្គលេខានៃគណបក្សហ៊្វុនស៊ិនប៉ិច បានច្រានចោលទាំងស្រុងថា លោកពុំបានទទួលដំណឹងនេះឡើយ ការពិតនោះ លោក កែ គីមយ៉ាន នៅក្នុងផ្ទះធម្មតា ដោយគ្រាន់តែពេលធ្វើដំណើរទៅណាមកណាមានមនុស្សឃ្លាំងមើលតែប៉ុណ្ណោះ ។

បើទោះបីជាអគ្គមេបញ្ជាការរូបនេះ គេមិនចាប់ខ្លួនក៏ពិតមែន ប៉ុន្តែក្នុងសភាពការណ៍នេះគាត់ទំនងជារស់នៅក្នុងសភាពភ័យខ្លាច និងត្រូវគេបំបិទមាត់ក៏អាចថាបាន ពីព្រោះគ្រប់សកម្ម-ភាពរបស់គាត់ត្រូវបានគេតាមឃ្លាំមើលគ្រប់ជំហាន ។ សូម្បីមិត្តភក្តិគាត់ដែលធ្លាប់រាប់រកនិងកូនចៅរបស់គាត់មួយចំនួនក៏មិនហ៊ានទាក់ទងគ្នាដែរ ។

ការដកអតីតអគ្គមេបញ្ជាការរូបនេះ មានព័ត៌មានចចាមអារ៉ាមខ្លះថា បណ្តាលមកពីលោកជំទាស់នឹងការតែងតាំង ហ៊ុន ម៉ាណែត កូនប្រុសរបស់ ហ៊ុន សែន ពីវរសេនីយ៍ឯក ទៅជាឧត្តមសេនីយ៍ត្រីផ្កាយមាស1 ដែលជាបញ្ជាការប្រឆាំងភេរវកម្មនៃក្រសួងការពារជាតិកាលពីកន្លងមកក្នុងការពង្រឹងអំណាច ។ កាលពីពាក់កណ្តាលខែកុម្ភៈ ហ៊ុន ម៉ាណែត ក៏ត្រូវបានក្រសួងការពារជាតិសំរេចដំឡើងស័ក្តិជាផ្លូវការ ។ ចំណែកលោក ទៀប ម៉ែន អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងការពាជាតិបានអះអាងថា ហ៊ុន ម៉ាណែត ត្រូវបានព្រះមហាក្សត្រ (តទៅទំព័រទី១៧)

AMERICAN LEGION POST 153
PRESENTS



FRANTIC
DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

សូមអញ្ជើញមកពីករាយ ពិសារភេសជ្ជៈ
រាំកំសាន្តនៅ "ម្រាចំណីក"

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

បន្ទប់បរិយាកាសយ៉ាងត្រជាក់ចិត្ត
បន្ទាប់ពីធ្វើការងារហត់នឿយ !



- កន្លែងកំសាន្តធំទូលាយ-ស្តាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬក៏បុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
- យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
- ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង៩ដល់ម៉ោង៣ព្រឹក DJ នឹងបណ្តែតអារម្មណ៍ លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ

ចង់ជួលសាល ឬចង់បានម្ហូប
ជប់លៀង យើងធ្វើជូនបាន !
HALL RENTAL & CATERING
AVALIABLE REASONABLE PRICE

សូមអញ្ជើញមកទស្សនា
ភាពយន្តជាមួយនារខ្ញុំ
YOU ARE INVITED TO MOVIE NIGHT
605 WOLF STREET.

ព្រះវិហារខ្មែរ មិនណូណៃ នៃ ទីក្រុងហ្វីឡាដែលហ្វា
PHILADELPHIA CAMBODIAN
MENNONITE CHURCH
605 WOLF ST. PHILADELPHIA, PA 19148




Snacks & Drinks
will be provided
Purpose: Strengthen
your marriage
& Family
Please call
215-468-4840,
or
267-243-7718
for more information.

ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩
ម៉ោង ៦: ៣០ ល្ងាច
MARCH 24Th, 2009
at 6:30 PM

# រដ្ឋាភិបាលបដិសេធរបាយការណ៍ Global Withness














**ឡុងប៊ិច, ខ្មែរប៉ុស្តិ៍៖ ហុង ម៉េងហ៊ាង**

•••អង្គការបរិស្ថានពិភពលោក ដែលតាមឃ្លាំមើលពីសកម្មភាពរដ្ឋមាន និងអរដ្ឋមាននៅលើពិភពលោក ជាពិសេសនៅប្រទេសកម្ពុជា បានចេញរបាយការណ៍ថ្មីមួយទៀតដែលមានចំណងជើងថា "ប្រទេសកម្ពុជាសំរាប់លក់" ហើយបានរិះគន់ពីមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ដែលប្រព្រឹត្តអំពើទុច្ចរិត និងបំផ្លិចបំផ្លាញសម្បត្តិធនធានធម្មជាតិនៅប្រទេសកម្ពុជា។

នៅក្នុងរបាយការណ៍នោះបានលាតត្រដាងពីឈ្មោះមន្ត្រីជាន់ខ្ពស់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោក ឱម យ៉ិនទៀង និងមេឈ្មួញធំៗ ដែលរកស៊ីកាប់បំផ្លាញព្រៃឈើ និងបានចេញអាជ្ញាប័ណ្ណរុករករ៉ែនៅបាតសមុទ្រស្ងាត់ៗ ។

របាយការណ៍ដែលមានកំរាស់70ទំព័ររបស់អង្គការ Global Withness បានបង្ហាញឈ្មោះមន្ត្រីជាន់ខ្ពស់មួយចំនួន ក្នុងនោះមានទីប្រឹក្សារបស់ ហ៊ុន សែន ឧត្តមសេនីយ៍យោធាមានលោក ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិ, លោក ប៉ុល សារឿន នាយឧត្តមសេនីយ៍កងយោពលខេមរភូមិន្ទ, លោក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និង លោក ឱម យ៉ិនទៀង លោក មាស សុភា មេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងឈ្មួញពីរនាក់ទៀតគឺឈ្មោះ ជឹង សុភាព និង ឡៅ ម៉េងឃីន .....។

ក្នុងរបាយការណ៍ដែលទើបនឹងចេញថ្មីលើកនេះ បានធ្វើមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជាមិនសប្បាយចិត្ត ។ ជាពិសេស លោក ឱម យ៉ិនទៀង បានធ្វើការវាយប្រហារតិះដៀលទៅលើ Global Withness យ៉ាងចាស់ដៃ ។

លោក ឱម យ៉ិនទៀង ដែលមានឈ្មោះក្នុងបញ្ជីខ្មៅបានចេញមុខការពារបក្ខពួករបស់ខ្លួន និងធ្វើការវាយប្រហារទៅលើអង្គការបរិស្ថាន ហើយចោទប្រកាន់ថា បញ្ចេញរបាយការណ៍មិនពិត និងចង់បង្ខូចកិត្តិយសរបស់ពួកគេ ។

ចំណែកឯកអគ្គរាជទូតខ្មែរប្រចាំចក្រភពអង់គ្លេសដែលគេស្គាល់ថា ជាកូនរបស់លោក ហោ ណាំហុង មិនបានទទួលស្គាល់ការពិតនៅរបាយការណ៍របស់ Global Withness ទាំងទទឹងទិសទៅវិញ ។

លោក ហោ ណាំបូរ៉ា ឯកអគ្គរាជទូតខ្មែរប្រចាំចក្រភពអង់គ្លេស បានមានប្រសាសន៍ថា របាយការណ៍របស់ Global Withness វាគ្មានអ្វីសំខាន់នោះទេ ហើយក៏មិនបានធ្វើឱ្យសហគមន៍ជាតិ-អន្តរជាតិ និងប្រទេសអ្នកផ្តល់ជំនួយចាប់អារម្មណ៍ឡើយ ។

ក្នុងរបាយការណ៍ចុងក្រោយនេះ Global Withness បានបង្ហាញពីភាពមិនប្រក្រតីជាច្រើនដែលទាក់ទងទៅនឹងការចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនបរទេសរុករករ៉ែប្រេងកាតនៅក្រោមបាតសមុទ្រ ដោយចំណាយលុយកាក់រាប់លានដុល្លារដើម្បីបានសិទ្ធិធ្វើអាជីវកម្ម ។

លោក សុខ អាន ប្រធានអាជ្ញាធរប្រេងកាតកម្ពុជាក៏បានអនុញ្ញាតឱ្យក្រុមហ៊ុនឥណ្ឌូនេស៊ីរុករកប្រេងកាតនៅឈូងសមុទ្រខ្មែរ ហើយក្រុមហ៊ុននេះបានចំណាយលុយ 7.5 លានដុល្លារឱ្យលោក សុខ អាន ។ ការចំណាយលុយរបស់ក្រុមហ៊ុនបរទេសទៅឱ្យមន្ត្រីជាន់ខ្ពស់បែបនេះ វាបង្កឱ្យអំពើពុករលួយកើតឡើងកាន់តែធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា ។ (តទៅទំព័រទី១៥)

Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់គ្នៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញអាជីវកម្ម |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

អិលធី សាលាសំអាងសម្ផស្សអន្តរជាតិ

LT INTERNATIONAL BEAUTY SCHOOL, INC.



*Hands on Training...*
*For a Better Future*

និស្សិតនឹងរៀនវិជ្ជាដោយផ្ទាល់ដៃ ដើម្បីឱ្យបានអនាគតល្អ ប្រសើរជាពិសេស
-យើងអាចទទួលសិស្សដែលមាន វីសា I-20 បាន សំរាប់រៀនរយៈពេលមួយឆ្នាំ ឬក៏យូរជាងនេះ
-យើងទទួលការដាក់ពាក្យពីប្រទេសក្រៅ ដូចជា: មកពីប្រទេសកម្ពុជាសំរាប់ការសិក្សា ។
ក្នុងករណីនេះ យើងរកផ្ទះឱ្យនៅនឹងម្ហូបអាហារផ្តល់ជូន
ប្រយ័ត្ន : យើងនឹងអាចរកជំនួយហិរញ្ញវត្ថុជូន សំរាប់តែនិស្សិតណាដែលមានសិទ្ធិ (គ្រួសារមានប្រាក់ចំណូលតិចតួច ឬគ្មានសោះ)

យើងជាសាលាដែលមានការទទួលស្គាល់ពីស្ថាប័នរដ្ឋ ខាងផ្នែកសំអាងសម្ផស្សរាប់ទាំង ការធ្វើសក់ ក្រចក ឬស្បែក ។
និស្សិតអាចជ្រើសរើសការសិក្សាវិញ្ញាសាដាច់មួយមួយក៏បាន




យក Coupon នេះមកជាមួយនឹង បញ្ចុះថ្លៃជូន $500
ចាប់ផ្តើមនៅថ្ងៃ ០៥ កុម្ភៈ ២០០៥

Financial-Aid available, for those who qualified

Office #1
830 N. Broad Street.
Philadelphia, Pa 19130
Tel : 215-922-4478
Fax : 215-763-2860

Office #2
2520-22 N. Broad Street.
Philadelphia, Pa 19132
Tel : 215-229-0390
Fax : 215-229-0391

www.ltinternationalbeautyschool.us Email: ltibs@verizon.net

(តមកនៅទំព័រទី០១) **តុលាការជម្រះក្ដីខ្មែរក្រហម : មាស មុត.....**

និងបង្កឱ្យមានអស្ថេរភាពនយោបាយជាតិជាមិនខានឡើយ ។

មាស មុត ដែលជាកូនប្រសារបស់ តាម៉ុក និងធ្លាប់ត្រួតទាហាន2ម៉ឺននាក់ នៅកងពលលេខ ១៦៤ និងស្ត្រី កុមារចំនួន5ម៉ឺននាក់ នៅតំបន់និរតី បានផ្ដល់បទសំភាសន៍ថា លោកមិនយល់ពីរបៀបស៊ើបការណ៍យ៉ាងម៉េចរបស់សាលាក្ដីខ្មែរក្រហមនោះទេ ប៉ុន្ដែលោកបញ្ជាក់ថា បើសិនជានាំខ្លួនជនសង្ស័យបន្ថែមទៀតនោះ នឹងបង្កឱ្យមានបញ្ហាអស្ថេរភាពនយោបាយក្នុងប្រទេសមិនខានឡើយ ។

អតីតឧត្ដមសេនីយ៍យោធាចូលនិវត្តន៍នៅតំបន់សំឡូតរូបនេះ មិនបានបញ្ជាក់អំពីមូលហេតុនៃអស្ថេរភាពនយោបាយយ៉ាងណានោះទេ ហើយលោកក៏មិនមានអារម្មណ៍ភ័យព្រួយដែរ គឺលោកត្រៀមខ្លួនចូលបំភ្លឺក្នុងតុលាការខ្មែរក្រហមក្នុងករណីចាំបាច់ ។

អ្នកនិពន្ធ Stephen Heder and Brian Tihemore បានសរសេរសៀវភៅមួយ ផ្សាយកាលពីឆ្នាំ ២000 ថា " បេក្ខជន៧នាក់ សំរាប់ការកាត់ទោស ហើយអ្នកនិពន្ធក៏បានចាត់ទុក មាស មុត ជាជនសង្ស័យផងដែរ " ។ ក្នុងឯកសារនោះក៏បានបង្ហាញពីភស្ដុតាងយ៉ាងច្បាស់ថា មាស មុត បានដឹកនាំកំលាំងយោធាទៅមន្ទីរស-២១ ដើម្បីបោសសំអាតកំលាំងនៅទីនោះ ។


មាស មុត មេដឹកនាំខ្មែរក្រហម


ឌុច ឡើងសាលាក្ដីខ្មែរក្រហម

មាស មុត ក៏បានបដិសេធថា គាត់មិនបានបញ្ជូនទាហានទៅមន្ទីរស-២១ ដែរ ហើយពលរដ្ឋខ្មែរ ដែលស្លាប់ជិត2លាននាក់នោះ មិនមែនសំលាប់ក្នុងរបបខ្មែរក្រហមដែរ គឺដោយសារច្បាំងជាមួយនឹងយួនទៅវិញទេ ។

អ្នកស្រី ជា លាង សហចៅក្រមខ្មែរ នៃសាលាក្ដីខ្មែរក្រហម ត្រូវបានកាសែតបរទេសស្រង់សំដីថា យើងត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវនីតិវិធីច្បាប់ ពីព្រោះរដ្ឋាភិបាលនឹងអង្គការសហប្រជាជាតិបានព្រមព្រៀងគ្នាបង្កើតសាលាក្ដីខ្មែរក្រហម ដែលចាត់ទុកថា ការផ្សះផ្សាជាតិ សន្តិសុខ សង្គម និងសន្តិភាពជារឿងសំខាន់ ។

ករណីនាំជនសង្ស័យក្នុងរបបវាលពិឃាតបន្ថែមនោះ មេធាវីអន្តរជាតិរបស់ នួន ជា ធ្លាប់បានស្នើទៅសហចៅក្រមខ្មែរ និងបរទេសម្ដងហើយដែរ ប៉ុន្ដែត្រូវបានច្រានចោលទៅវិញ ដោយលើកហេតុផលថា ខ្ញុំគ្មានជំនឿថា តុលាការកោះហៅរូបគាត់ដែរ បើទោះបីជាកោះហៅក៏គ្មានប្រយោជន៍ដែរ ពីព្រោះគាត់គ្មានចំណែកក្នុងការសំរេចចិត្តនោះទេ ។

ចំពោះការព្រមានពីអត្ថិភាពនយោបាយក្នុងប្រទេស អ្នកស្រុកនៅតំបន់សំឡូតបានបញ្ចេញប្រតិកម្មថា ប្រសិនបើសាលាក្ដីខ្មែរក្រហមចាប់ខ្លួន មាស មុត គឺវាគ្មានបង្កបញ្ហាអ្វីនោះទេ ពីព្រោះរដ្ឋាភិបាល ហ៊ុន សែន មិនអនុញ្ញាតឱ្យមានបញ្ហាសង្គ្រាមម្ដងទៀតឡើយ ។

ការលើកឡើងរបស់អ្នកស្រុកនៅតំបន់សំឡូត ត្រូវបានមជ្ឈដ្ឋាននានាយល់ថា ពីព្រោះខ្មែរក្រហមបានរលាយអស់នូវអង្គការចាត់តាំងគ្មានព្រៃរត់ចូលបង្កសង្គ្រាមដូចទសវត្សរ៍ឆ្នាំ៧0ឡើយ ។

ចំណែក មាស មុត ក៏បានបញ្ជាក់ស្រដៀងនិងការលើកឡើងខាងលើដែរថា គាត់បានត្រៀមខ្លួនជានិច្ច មិនរត់គេចទៅទីណាទៀតទេ ពីព្រោះពេលនេះ វាអស់ព្រៃ និងអស់មនុស្សដែលមានទឹកចិត្តដូចគាត់ហើយ ។

មន្ត្រីអង្គការ-សហាគមឃ្លាំមើលសាលាក្ដីខ្មែរក្រហម ក្នុងការកាត់ក្ដីអតីតមេដឹកនាំខ្មែរក្រហម ក៏បានបញ្ជាក់ថា ការនាំខ្លួនជនសង្ស័យឡើងតុលាការពេលនេះ វាមានចំណុចល្អច្រើន ប៉ុន្ដែក្នុងច្បាប់ដែលគេបានកំណត់ឱ្យកាត់ទោសតែមេដឹកនាំខ្មែរក្រហម ដែលជាប់ពាក់ព័ន្ធតែប៉ុណ្ណោះ ។ ពួកគេបានសំដែងនូវការព្រួយបារម្ភពីដំណើរការយឺតយ៉ាវរបស់តុលាការ និងការឱ្យសាក្សីជនរងគ្រោះរួចតិចតួច ពេលបើកសវនាការ ឌុច កន្លងទៅផងដែរ ៕


**Randolph C. Smith**




Attorney at Law

267-324-6503

Office # 1
1819 JFK Blvd.
Philadelphia, Pa 19103

Office # 2
1115 S. 11th St.
Philadelphia, Pa 19147

ការិយាល័យច្បាប់យើងខ្ញុំ មានចំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ ការរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីឧក្រិដ្ឋកម្ម និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក សុធា : (267) 324-6503

We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Imminration.

We will take care of your car and everything else without your pochet expense.
Please contact Sothia at 267-324-6503 for more information.

**The Noni Juice**

ទឹកផ្លែមផ្លែ"ណូនី"ខ្មែរហៅផ្លែ"ញ"ត្រូវគេចងចាំថា ឪពុកម្ដាយ ឬជូនតា ធ្លាប់យកផ្លែ "ញ" នេះទៅត្រាំស្រា ហើយពិសារជាថ្នាំព្យាបាលការឈឺចុកចាប់នានា បណ្ដាលឱ្យមានកម្លាំង-ចុះកម្លាំងឈាម ។ល។ ឥឡូវនេះ អ្នកវិទ្យាសាស្ត្រខាងពេទ្យរកឃើញថា ផ្លែ"ញ" នេះ បើប្រើឱ្យសុទ្ធគ្មានលាយជាតិគីមីនឹងធ្វើឱ្យចុះសម្ពាធឈាមបន្ថយការឈឺសន្លាក់ដៃជើងព្យាបាលជំងឺទឹកនោមផ្អែម-ធ្វើឱ្យមានកម្លាំង និងជួយរំលាយអាហារទៀតផង។
សូមទាក់ទងតាមឈ្មោះ និងទូរស័ព្ទខាងក្រោម ដើម្បីជាវទឹកផ្លែម"ណូនី"




Philadelphia: David: 215-268-4821 or Jason: 215-805-3396
Rhode Island: Hui Le: 401-640-5158
Lowell: Samran: 508-216-6062
The Noni Jucie is made by traditional method, 100% pure, and no preservation. It can help decrease high blood pressure; reduce arthritis pain, diabetes, increase body energy level and digestion system.

**Repro Center**
怡保印刷中心
*the printer you can trust*
*Since 1993*

1531-33 South 7th Street
Philadelphia • PA 19147
**T: 215.271.5041 /5042**
F.: 215.271.5043 • reprocenter@usa.net

- **Fast, Easy Print Ordering**
- **Premium Quality**
- **Low Price**
- **Excellent Customer Service**

BUSINESS CARDS as low as $15





## សេវាបោះពុម្ព

- តារាងម្ហូបភោជនីយដ្ឋាន
- លិខិតចំលងគ្មានកាបូន
- ខតអស័យដ្ឋាន
- ស្រោមសំបុត្រ
- ថតចំលងពណ៌ឌីស៊ីតុល
- សេវាបញ្ជូនលិខិត
- កាតាឡុកសៀវភៅ
- ខិត្តប័ណ្ណបត់ជាសៀវភៅ
- ខិត្តប័ណ្ណលាត
- រូបផ្ទាំងស្អាដតូចៗ
- ផ្ទាំងរូបផ្ទាំងស្ទរធំៗ
- ប្រតិទិន
- ធ្វើហ្វូលឌ័រសំរាប់ផ្សាយ
- បកប្រែភាសា
- គូសក្រាហ្វិក
- ធ្វើត្រាមាស
- អ៊ុតលើក្រប
- ធ្វើក្រប
- ប៉ាក់លើក្រណាត់ ឬសូត្រ






**Services Products**

Restaurant Menu
Carbonless NCR Form
Business Cards
Envelopes
Letterhead
Digital Color Copy
Mailing Services

Catalogs / Booklets
Brochures
Flyers
Postcards
Posters
Calendars
Presentation Folder

Translation
Graphic Design
Gold Foil Stamping
Laminating
Labels
Clothing Embroidery / Silk Screen

---

មានជួសជុលកែតម្រូវ
អាវ ខោ សំពត់
*Professional alternation
*We do LEATHERS!

ទើបបើកថ្មី
# ហាងសំអាត
## សំលៀកបំពាក់ស្ងួត DRY CLEAN

# GRAND OPENING
## MENG´S CLEANERS

454e Wyomimng Ave.Philadelphia Pa 19120
**TEL : 215-329-2593**

ប្រើម៉ាស៊ីនសំអាតគ្មានជាតិគីមី
ORGANIC MACHINE

**ចុះថ្លៃ 20 %**
**20 % OFF**
Start -11/16/08, End-01/16/09
ចុះតម្លៃពីថ្ងៃ ១១/១៦/០៨ ដល់ ០១/១៦/០៩



















នាទី ប្រវត្តិសាស្ត្រ

## ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

**ឆ្នាំ ១៩៦៥**

**១០ មករា :** លិខិតផ្លូវទូតខ្មែរ បញ្ជូនតាម-រយៈស្ថានទូតបារាំង ទាមទារឱ្យរដ្ឋាភិបាលវៀតណាមខាងត្បូងប្រគល់ដែនដី ដែលគ្រប់គ្រងដោយរដ្ឋបាលឥណ្ឌូចិន ឱ្យប្រគល់មកខ្មែរវិញ ។

**១៤ កុម្ភៈ :** បើកសន្និសីទនៃប្រជាជនឥណ្ឌូចិនដំបូងបង្អស់នៅភ្នំពេញ ។

**២៦ មេសា :** បាតុកម្មប្រឆាំងនឹងអាមេរិកនៅមុខស្ថានទូតអាមេរិកាំង ។

**៣ ឧសភា :** កម្ពុជាផ្តាច់ទំនាក់ទំនងទូតជាមួយសហរដ្ឋអាមេរិក ។

**៧ ឧសភា :** ទ្រង់នរោត្តម កន្តុល រៀបចំគណរដ្ឋមន្ត្រីសង្គមរាស្ត្រនិយម គណរដ្ឋមន្ត្រីសង្គមទី២១

**នរោត្តម កន្តុល (7.5.1965-26.10.1966)**

-នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ : នរោត្តម កន្តុល

-ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ នឹងកីឡា លន់ នល់

-ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីសំរបសំរួលកិច្ចការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងផែនការណ៍ : សឹង សាន

-ទេសរដ្ឋមន្ត្រីទទួលបន្ទុកអប់រំជាតិ : ស៊ីសុវត្ថិ សិរិមត :

-រដ្ឋមន្ត្រីឧស្សាហកម្ម : ផ្លែក ឆាត

-រដ្ឋមន្ត្រីយុត្តិធម៌ : ប៉ុនវង្ស វឌ្ឍី

-រដ្ឋមន្ត្រីការបរទេស : គន់ វិច

-រដ្ឋលេខាធិការសាធារណៈ និងទូរគមនាគមន៍ : អ៊ុំង គាត

-រដ្ឋលេខាធិការពាណិជ្ជកម្ម : សូណែម

-រដ្ឋលេខាធិការផែនការ : ចៅ សៅ

-រដ្ឋលេខាធិការព័ត៌មាន : ជា សាន

-រដ្ឋលេខាធិការការងារ និងសង្គមកិច្ច : លោកស្រី ទិប ម៉ម

-រដ្ឋលេខាធិការកសិកម្ម : ជួន សៅឌី

-រដ្ឋលេខាធិការសុខាភិបាល : ឆាយ ហាន់ចេង

-រដ្ឋលេខាធិការហិរញ្ញវត្ថុ : យ៉ែម សារ៉ុង

-អនុរដ្ឋលេខាធម្មការ : ទ្រិញ វ៉ាញ

-អនុរដ្ឋលេខាធិការអមទីស្តីការគណរដ្ឋមន្ត្រីទទួលបន្ទុករាជមន្ទីរទេសចរណ៍ : អាំង គិមឃន

-អនុរដ្ឋលេខាធិការអប់រំជាតិ : សិរិត សុទ្ធ

-អនុរដ្ឋលេខាមហាផ្ទៃ : ហែម កេតសាណា ។ **(តនៅលេខក្រោយ)**

mann Since 1909
Funeral Home, INC.
219 West Tabor Road .
Philadelphia, PA 19120
(215) 458-3282
Henry S. Mann 1915-1993 H.Craig Mann Supervesor Frederick mann, Jr. Founder
A CENTURY of Excellence to the Delaware Valley
Proudly serving Asian Communities for over 48 years.
ឈាបនដ្ឋាន
"ម៉េន"
➪ បម្រើសហគមនតាំងព១០០ឆ្នាំមកហើយ មានទីកន្លែងសមរម្យធ្វើពិធីតម្កល់សព ។
➪ មានក្តារមឈូសអាចបូជា ឬបញ្ចុះសព នៅ ២០ឆ្នាំចុងក្រោយនេះ យើងមានសេវាបម្រើសហគមន៍ខ្មែរ ឱ្យអាចធ្វើបុណ្យតាមប្រពៃណីជូនដំណើរអ្នកដែលបានចែកឋានទៅ ។
បើសិនមានសំណួរ សូមទាក់ទងទៅ :
Craig MANN : (215) 548-3292

# ពុទ្ធប្បវត្តិអមដោយរូបភាព

## A Pictorrial Biography of Saky amuni Buddha

**ដោយ : អ៊ុម ឈឿម (តពីលេខមុន)**

❖រូបភាព និងរឿងដើមជា ភាសាថៃ ដោយ គុណាប៉ាយុតា

❖បកប្រែជាភាសាចិន ដោយ ភិក្ខុ ជែន ហាយ

❖បកប្រែជាភាសាអង់គ្លេស ដោយ ហ្សិត .អេ.លី

❖ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី

❖បកប្រែជាភាសាខ្មែរ ដោយភិក្ខុ គង់ អាំ

❖Original Illuatra- tion and Naration in Thai by Gunapayuta.

❖Translation into Chinese by Bhikkhu Jan Hai.

❖Translation into English by Z.A Lu.

❖ Coloring by Yann-Fang Lee

❖Translation into Khmer by Bhikkhu Kong Am.



ដូច១គ្នា "ព្រះអង្គម្ចាស់រាជកុមារ កាលបើទ្រង់ស្នងរាជពីព្រះបិតា ព្រះអង្គនឹងបានជាស្តេចចក្រពត្តិលើស្តេចនគរដទៃ១ទៀត នេះម្យ៉ាង ម្យ៉ាងទៀត បើព្រះអយ្យបុត្រចេញចាកផ្ទះ ដើម្បីស្វែងរកព្រះពោធិញ្ញាណវិញ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធដោយពិត" ។ ចំណែកព្រាហ្មណ៍ម្នាក់ទៀតដែលមានវ័យក្មេងជាងគេ ឈ្មោះ **កោណ្ឌញ្ញ** បានទាយបញ្ជាក់យ៉ាងសុក្រឹត្យ តែម្យ៉ាងថា "នៅពេលដែលព្រះសិទ្ធត្ថរាជកុមារទ្រង់មានវ័យចំរើនឡើង ព្រះអង្គនឹងលះបង់រាជបល្ល័ង្គស្វែងរកព្រះពោធិញ្ញាណ ហើយព្រះអង្គនឹងសំរេចនូវសព្វញ្ញុតញ្ញាណបានជាសាស្ត្រាចារ្យឯកក្នុងលោក " ។

**១២**-ប្រជារាស្ត្រ និងមន្ត្រីទាំងឡាយក្នុងព្រះនគរចង់ឱ្យព្រះរាជកុមាសោយរាជសម្បត្តិជាស្តេចចក្រពត្តិនៅពេលដែលព្រះអង្គមានព្រះជន្មពេញវ័យ ។ ព្រះបាទសុទ្ធោទនៈ វិញក៏មានព្រះបំណងដូច្នោះដែរ ។ អ្វីដែលព្រះអង្គសង្ឃឹមទុកនោះទ្រង់ចង់ឱ្យព្រះ-អង្គម្ចាស់មានគ្រួសារប្រពន្ធកូនដូចជាអស់មនុស្សផងទាំងពួង និងជាអ្នកស្នងព្រះអង្គ ក្នុងការគ្រប់គ្រងព្រះនគរនៅពេលទ្រង់មានវ័យចំរើនធំឡើង ។



12- The peoper and scholars of the country all wished for the prince to become a Cakravarti when he grew up. King Suddhodana wished for this too. He certainly did not want his son to leave home and become a teacher, for he expercted the prince, when the time came, to have a family like other human being, raise children, and succeed him in ruling the country.

**១៣**-រយៈពេលពីរថ្ងៃ ក្រោយពិធីថ្វាយព្រះនាមព្រះរាជកុមារ ព្រះនាងមហាមាយា រាជទេវីទ្រង់សោយទីវង្គត់ ដោយព្រះរោគាពាធ ។ មនុស្សម្នាទាំងឡាយយំសោកទង្គឹះខ្សឹកខ្សួលគ្រប់១គ្នាចំពោះមរណៈទុក្ខនេះ តែអ្នកដែលកើតទុក្ខក្រៀមក្រំជាងគេ គឺអង្គព្រះសុទ្ធោទនៈ ជាព្រះស្វាមីព្រះនាងដោយសារតែព្រះនាងមាយាជាស្ត្រីមានវណ្ណៈខ្ពស់ថែមទាំងជាស្ត្រីមានលក្ខណៈសម្បត្តិល្អបំផុតក្នុងចំណោមស្ត្រីក្នុងព្រះរាជវាំង ។

**(តនៅលេខក្រោយ)**

**13**- Two days after the prince was named, queen Maya died of some illness. Every body was grief-stricken at this turn of events, but the saddest person was, of course, her husband King Suddhodana, for queen Maya wsa a woman of the higtheest caste and also the most virtuous of the ladies of the court.

**(continue Issue After)**

(តមកពីទំព័រទី១២)

# រដ្ឋាភិបាលបដិសេធរបាយការណ៍...



ឈើហុបដែលឈ្មួញកាប់ដឹកតាមរថយន្តយកទៅលក់នៅប្រទេសសៀម



ដីរបស់ប្រជាពលរដ្ឋត្រូវអាជ្ញាធររឹបអូសយកលក់ឱ្យឈ្មួញ

ចំណែកលោក ទៀ បាញ់ និងលោកនាយឧត្តមសេនីយ៍ ប៉ុល សារឿន ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងការពារជាតិ បានបដិសេធចំពោះរបាយការណ៍របស់អង្គការ Global Withness ដែលមិនគួរឱ្យជឿ និងទុកចិត្តបានឡើយ ហើយចេះតែនិយាយផ្ដេសផ្ដាសគ្មានហេតុផល ។

រីឯ ហ៊ុន សែន ដែលអង្គការ Global Withness ចោទប្រកាន់ថា ជាមេខ្លោងក្នុងការបំផ្លិចបំផ្លាញជាតិនោះ ក៏មានប្រតិកម្មទាំងកំហឹងក្រេវក្រោតថា នេះជារបាយការណ៍ឆ្កួតលីលាគ្មានហេតុផលទាល់តែសោះ ហើយចេះតែសរសេរតាមចិត្តនឹកឃើញ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ថ្នាក់ដឹកនាំប្រទេសកម្ពុជាទៀតផង ។

ទាក់ទិនទៅនឹងការច្រាលចោលរបស់មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជានេះ ខាងអង្គការសង្គមស៊ីវិលបែរជាសម្ដែងនូវការគាំទ្រចំពោះរបាយការណ៍អង្គការ Global Withness ទាំងពីរលើក ហើយបានហៅរបាយការណ៍នេះថា ជាសារមួយដ៏ល្អសំរាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ធ្វើការពិចារណាផងដែរ ។

ជាក់ស្ដែងក្នុងរបាយការណ៍របស់ Global Withness កាលពីឆ្នាំ 2007 ដែលដាក់ចំណងជើងថា **"សែស្រឡាយអ្នកលក់ជាតិ"** ក្នុងរបាយការណ៍នោះ មានឈ្មោះរបស់នាយករដ្ឋមន្ត្រីខ្មែរសាច់ញាតិបានឃុបឃិតគ្នាបើកដៃឱ្យឈ្មួញកាប់បំផ្លាញព្រៃឈើស្ទើរអស់ ។

តាមរយៈរបាយការណ៍នេះផងដែរ លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ក៏បានយករបាយការណ៍នេះ ទៅឃោសនាប្រាប់ប្រជាពលរដ្ឋឱ្យដឹងពីមុខមាត់អ្នកបំផ្លិចបំផ្លាញជាតិ ។ ប៉ុន្តែលោកត្រូវបានគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតបានប្ដឹងលោកពីបទរំលោភច្បាប់បោះឆ្នោតឡើងតុលាការរហូតដល់សព្វថ្ងៃ ហើយតំរូវឱ្យបង់ប្រាក់ចំនួន10លានរៀលពីបទជេរប្រមាថថ្នាក់ដឹកនាំគណបក្សប្រជាជន។

ប៉ុន្តែលោក សម រង្ស៊ី នៅតែប្រកាន់ជំហរថាពុំបានជេរប្រមាថអ្នកណាទេ គឺលោកនិយាយតែតាមរបាយការណ៍របស់ Global Withness ដែលបានចុះផ្សាយឱ្យពិភពលោកដឹងពីទង្វើអាក្រក់របស់អ្នកបំផ្លិចបំផ្លាញជាតិតែប៉ុណ្ណោះ ។

សំរាប់ប្រជាពលរដ្ឋខ្មែរ និងមន្ត្រីរាជការមួយភាគធំបានសម្ដែងការគាំទ្រចំពោះរបាយការណ៍របស់ Global Withness ធ្វើការប្រៀបធៀបឃើញថា ធនធានធម្មជាតិនៅប្រទេសកម្ពុជា ពិតជាត្រូវបំផ្លាញដោយអ្នកមានអំណាចមួយចំនួនពិតមែន ។

ជាមួយគ្នានេះដែរ ក្នុងរបាយការណ៍ថ្មីដែលមានចំណងជើងថា "ប្រទេសសំរាប់លក់" នៅពេលបច្ចុប្បន្ន ត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីអស់ គឺព្រៃឈើ ដីស្រែ ភ្នំ ស្ទឹង ដងអូរ សមុទ្រ សំណង់អគារក៏ត្រូវបានគេលក់ឱ្យឈ្មួញក្រោមរូបភាពអភិវឌ្ឍន៍ទាំងនៅទីក្រុង និងជនបទ ។

ជាឧទាហរណ៍រ៉ែមាសនៅរតនៈគីរី មណ្ឌលគីរី ព្រះវិហារ បន្ទាយមានជ័យ ឧត្ដរមានជ័យ បាត់ដំបង ប៉ៃលិន....ត្រូវបានពួកឈ្មួញធ្វើអាជីវកម្ម ដោយគ្រឿងចក្ររុករកនៅក្រោមដីអស់គ្មានសល់ ។ ចំណែកឯនៅបាតសមុទ្របច្ចុប្បន្នមានក្រុមហ៊ុនរុករកប្រេងបរទេសជាងដប់ បាននិងកំពុងទទួលសិទ្ធិរុករក និងធ្វើអាជីវកម្ម ដោយពួកគេត្រូវបង់លុយឱ្យមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលស្ងាត់ៗ ។

ទាក់ទិនទៅនឹងការលើកឡើងរបស់ Global Withness មន្ត្រីរាជការម្នាក់ក្នុងលក្ខខណ្ឌសូមមិនបញ្ចេញឈ្មោះបានលើកឡើងថា មិនថាតែព្រៃឈើ ដីព្រៃ ដីរបស់ប្រជាពលរដ្ឋដែលមានម្ចាស់ហើយនោះ ក៏ត្រូវអាជ្ញាធរឃុបឃិតជាមួយថ្នាក់លើលក់ឱ្យឈ្មួញស្ទើរគ្រប់ទីកន្លែងធ្វើឱ្យរាស្ត្រស្រែកយំ និងរស់នៅក្នុងសភាពភ័យខ្លាចក្រលំបាកកាន់តែខ្លាំងពីមួយថ្ងៃទៅមួយថ្ងៃទ្វេឡើង។

ប្រភពខាងលើបានបញ្ជាក់ថា កន្លងមក និងពេលបច្ចុប្បន្ននៅតាមក្រសួងមន្ទីរមួយចំនួនបានលក់អគារចាស់ៗដែលជាសមិទ្ធិផលនៅសម័យសង្គមរាស្ត្រនិយមស្ទើរអស់ ហើយយកលុយចែកគ្នាចាយ ក្រោមរូបភាពផ្លាស់ប្ដូរទីតាំងកន្លែងធ្វើការឱ្យកាន់តែឆ្ងាយប៉ុណ្ណោះ ។

ការលើកឡើងខាងលើនេះវាស្របនឹងកំណាព្យរបស់លោក ម៉ម សូណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំ ដែលបានចាក់ផ្សាយជារៀងរាល់ថ្ងៃ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរធ្វើការពិចារណាពីទង្វើរបស់អ្នកដឹកនាំបច្ចុប្បន្ន ដែលបានលក់កេរដំណែលវប្បធម៌ និងធនធានធម្មជាតិ ទៅឱ្យពួកឈ្មួញគ្មានការខ្មាសអៀន ។ (តទៅទំព័រទី១៩)


## ចង់ចេញពីភាពទ្រុឌទ្រោម? RELIV អាចប្ដូររូបរាងកាយឱ្យមាំទាំបាន



Dr. Earleen Ong, Fellow of Geriatric Medicine, Certified Family Physician
Dr. John Harold Ong, Orthomolecular Medicine, Associate of Geriatric Medicine

**Reliv: Nutrition for the 21st Century**

Today's modern processing techniques rob essential nutrients from much of our food. Reliv restores the balance by delivering a unique blend of the vitamins, antioxidants, minerals, proteins, amino acids and phytonutrients the body needs to restore energy, fight off infections and feel great — every day.




WWW.RELIV.COM

☞ ពិសារ Reliv រាល់ថ្ងៃ គឺនាំឱ្យមានកម្លាំងកាយ រូបរាងមាំមួន សម្ផស្សស្រស់បស់ឡើងបាន

☞ Reliv អាចទប់ស្កាត់នូវជំងឺមួយចំនួនធំ ដែលកើតមកពីការពិសារចំណីអាហារខ្វះជីវជាតិ ធ្វើឱ្យសរីរាង្គគាំងដំណើរ

☞ ពិសារ Reliv លោក-អ្នកនឹងដឹងពីប្រសិទ្ធភាព ចាប់តាំងពីថ្ងៃដំបូង ដែលលោក-អ្នកប្រើ Reliv នេះភ្លាម ។

សូមទូរស័ព្ទជាវនៅលេខ : (636) 537 9715
. ដោយផ្ដល់លេខសំគាល់ : RNC .7070 438001
បញ្ជាទិញ 1. RELIV CLASIC មួយកំប៉ុង
2. Reliv INNERGINE មួយកំប៉ុង ដែលជាចំណីជីវជាតិ
លាយ RELIV 1 និង RELIV 2 ម្នាងមួយស្លាបព្រាក្នុងទឹកផ្លែឈើហើយពិសារម្ដង ឬពីរដងក្នុងមួយថ្ងៃ ទៅតាមភាពទ្រុឌទ្រោមនៃរូបរាងកាយ
" ភាពរឹងមាំកើតឡើងស្ទើរជឿមិនបាន "

**ម្យ៉ាងវិញទៀត : នៅពេលឃើញប្រសិទ្ធភាពនៃ Reliv លោកអ្នកនឹងមានជំនឿថា អាចចែកចាយឱ្យមនុស្សច្រើនទៀតបាន**

សូមទាក់ទងមកយើងខ្ញុំ ដើម្បីចុះឈ្មោះជា RELIV DISTRIBUTOR បន្តទៅទៀត លោកអ្នកអាចនឹងចំណេញប្រាក់ច្រើន ដោយសារតែបានជួយអ្នកដទៃឱ្យមានសុខភាពល្អដូចលោកអ្នកបាន ទូរស័ព្ទនៅ Philadelphia : **(267) 254 8758**
នៅ **VIRGINIA 703 415- 6257**

# ART OF WELLNESS CENTER



Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com



មន្ទីរសុខភាព "Art of Wellness" ទទួលព្យាបាលបញ្ហាផ្លូវចិត្តនឹងកាយធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក របៀបបច្ចេកទេស និងបច្ចេកវិទ្យាបច្ចិមប្រទេស ។

**ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម:**

- ធ្លាក់ទឹកចិត្ត DEPRESSION
- ការថប់អារម្មណ៍ ANXIETY
- ភាពតានតឹង STRESS
- មានកំហឹងច្រើន ANGER MANAGEMENT
- ឈឺខ្លួនប្រាណគ្រប់កន្លែង PAIN MANAGEMENT
- មានវិបត្តិក្នុងគ្រួសារ FAMILY ISSUES
- ការញៀន និងអ្វីមួយ ADDICTION ISSUES
- សុខភាពស្ត្រី WOMEN'S HEALTH

**ទទួលព្យាបាលបានគ្រប់វ័យ**

| របៀបព្យាបាល | TREATMENT TYPE |
| --- | --- |
| ប្រើម្ជុលឥតថ្នាំ | Acupuncture |
| ចាប់សរសៃ | Acupressure |
| ចិត្តវិទ្យា | Psychotherapy |
| យោគ/ ភាវនា | Yoga / Meditation |

**វេជ្ជបណ្ឌិតនិងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំ នៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ។**

**សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល**

ART OF WELLNESS CENTER
647 BAINBRIDGE SREET
PHILADELPHIA, PA 19147
215-305-2238

**ភាសាខ្មែរទាក់ទង ប៊ុន រ៉ាត : 267-242-8526**





**តាមការស្រាវជ្រាវគេបានរកឃើញថា ទឹកមិនត្រឹមតែជួយឱ្យមានជីវិតរស់នៅយ៉ាងឋិតថេរទេ ថែមទាំងជួយឱ្យស្ត្រីមានសម្រស់ដ៏ផូរផង់ទៀតផង ។**

**-មុនចូលដំណេក :** ទទួលទានទឹកមួយកែវ នឹងជួយកាត់បន្ថយភាពស្រេកឃ្លានទឹកនៅពេលពាក់កណ្តាលយប់ ជាពិសេសជួយឱ្យមានតុល្យភាពទឹកនៅក្នុងរាងកាយ ដែលត្រូវបាត់បង់ពេលទទួលទានដំណេកតាមរយៈខ្យល់ដកដង្ហើម ការបញ្ចេញជាតិញើសជាដើម ។

**-ភ្ញាក់ពេលព្រឹក :** ច្របាច់ក្រូចឆ្មារចូលក្នុងទឹកស្អាតល្អ ហើយទទួលទាននឹងជួយដាស់អារម្មណ៍គ្រប់ផ្នែកក្នុងរាងកាយឱ្យបាត់ងងុយដេក ឬស្វាងដោយភាពងងុយបាន។ ជាមួយគ្នានេះ រសជាតិជូររបស់ក្រូចឆ្មារនៅជួយជំរុញឱ្យមានភាពស្រស់ស្រាយទូទាំងរាងកាយបានផង ។

**-ងូតទឹក :** ការងូតទឹកអាចជួយឱ្យស្បែកមានសំណើមមិនស្ងួតសោះកក្រោះ ។ ជាទូទៅស្ត្រីប្រើពេលងូតទឹកគិតជាមធ្យម១២នាទី ។ អ្នកឯកទេសបានធ្វើការណែនាំឱ្យស្ត្រីប្រើពេលងូតទឹកប្រចាំថ្ងៃក្នុងមួយលើក១ ត្រឹម៥នាទី ជាការគ្រប់គ្រាន់ ហើយត្រូវជូតខ្លួនឱ្យបានថើ១ មានសំណើមទឹកនៅជាប់លើខ្លួនឱ្យបានច្រើនជាការប្រសើរបំផុត ។ ក្នុងថ្ងៃណាដែលមានអារម្មណ៍តឹងតែងអ្នកអាចប្រើទឹកសម្រាប់បំបាត់អាការៈ នេះចេញពីខ្លួនក៏បាន ។

វិធីបំបាត់មានច្រើនបែបទៅតាមអ្នកចូលចិត្ត និងភាពងាយស្រួលតែប៉ុណ្ណោះ ធ្វើយ៉ាងណាឱ្យមានអារម្មណ៍ធូរស្បើយនិងមានសេចក្តីសុខ។

**-ត្រាំក្នុងទឹក :** បើកទឹកក្តៅឧណ្ហៗ ឱ្យ ពេញអាងរួចហើយប្រើខ្ទីដែលចិតជាបន្ទះស្តើងៗចាក់ចូលក្នុងអាងទឹកនោះ ត្រាំទុកចោលមួយសន្ទុះ ហើយអ្នកចូលដេកត្រាំខ្លួនឱ្យបានប្រហែល២០នាទី នឹងអាចជួយបន្ថយភាពតឹងតែងនៃសាច់ដុំជួយស្បែកឱ្យបញ្ចេញញើសតាមរន្ធរោមបានច្រើនឡើង ។ ពេលដេកត្រាំទឹកនេះ គួរទទួលទានទឹកស្អាតខ្លះៗផង ដើម្បីការពាររាងកាយពីការខ្វះខាតទឹក ។ អ្នកអាចធ្វើក្នុងមួយសប្តាហ៍មួយលើកក៏គ្រប់គ្រាន់ មិនដូច្នេះស្បែកនឹងឡើងស្ងួតសោះកក្រោះ។

**-ចាក់ទឹកលើស្បែក :** បើកទឹកផ្កាឈូក តិចៗ ចរន្តទឹកនឹងធ្លាក់កាត់ស្បែកមុខថ្នមៗ និងយឺតៗ ។ ដាក់ផ្កាឈូកឱ្យឃ្លាតឆ្ងាយពីស្បែកប្រហែល ៩សង់ទីម៉ែត្រ ដើម្បីកុំឱ្យកម្លាំងទឹកប៉ះត្រូវស្បែកខ្លាំងពេក ដែលវិធីនេះអាចជួយឱ្យស្បែកមានសំណើម និងមានភាពស្រស់ថ្លាឡើងយ៉ាងឆាប់រហ័ស ។

**-តម្រូវការទឹកក្នុងមួយថ្ងៃ :** តម្រូវការទឹកនៃសរីរាង្គកាយរបស់មនុស្សយើងម្នាក់ៗមានសភាពខុសប្លែកពីគ្នា និងទៅតាមរដូវកាល ។ ក្នុងរាងកាយរបស់យើងមានទឹកលាយផ្សំប្រហែល៧០% នៃទម្ងន់រាងកាយទាំងមូល ។ នៅត្រង់ស្បែក បើសិនខ្វះខាតទឹក នឹងនាំឱ្យស្បែកកើតស្នាមជ្រីវជ្រួញ ឆាប់រហ័សជាងធម្មតា ហើយបង្កឱ្យកើតការឆាប់ចាស់បានបំផុត ។ ទទួលទានមិនត្រឹមត្រូវ តែជួយនូវផលប្រយោជន៍ទាំងអស់នោះទេ ប៉ុន្តែបើសិនខ្វះខាតទឹកនេះ នឹងធ្វើឱ្យឆាប់អស់កម្លាំងកំហែងសាច់ដុំថមថយថាមពល និងផលប៉ះទង្គិចរយៈពេលយូរអង្វែង គឺនាំឱ្យកើតអាការឈឺខ្នង, ឈឺសន្លាក់, ទល់លាមក និងឬសដូងបាតបានផង ។ ស្ត្រីគ្រប់រូបគួរចងចាំទុកថា មិនត្រូវទទួលទានទឹក តែចំពោះការស្រេកប៉ុណ្ណោះទេ គួររកទទួលទានឱ្យបានគ្រប់ពេល បើមិនដូច្នេះទេ អ្នកនឹងស្ថិតក្នុងសភាពរាងកាយខ្វះខាតទឹកពុំខាន ។ បើទឹកក្នុងរាងកាយថយចុះត្រឹមតែ២% នឹងនាំឱ្យប៉ះពាល់ដល់ភាពចងចាំក្នុងរយៈពេលខ្លី ៕

# សុខភាព វិធីបំបាត់អាការៈស្រៀវធ្មេញ

**ប្រសិនបើពោលពីអាការៈជម្ងឺដែលពាក់ព័ន្ធទៅនឹងធ្មេញនរណាៗក៏គេលាន់មាត់ទទួលស្គាល់ថា អាការៈជម្ងឺបែបនេះបង្កបាននូវទុក្ខវេទនាស្ទើរតែជាប់លំដាប់ទី១ឯណោះ ទោះបីជាស្របពេលគ្នា នោះមានពាក្យមនុស្សពោលថា រាល់ជម្ងឺទាំងអស់វាមិនស្រួលក៏ដោយចុះ។ ពេលនេះអ្នកដែលមានអាការៈស្រៀវធ្មេញ អាចពិនិត្យមើលខ្លឹមសារខាងក្រោមនេះ ដែលយើងនឹងលើកយកវិធីណែនាំបំបាត់អាការៈ ស្រៀវធ្មេញបែបងាយៗដូចខាងក្រោមនេះ :**



**1-**ណែនាំឱ្យអ្នកប្រើថ្នាំដុះធ្មេញ និងថ្នាំខ្ពុលមាត់ដែលមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអាការៈស្រៀវធ្មេញរយៈពេលប្រមាណ ៦-៨សប្តាហ៍ ដែលអាចប្រើបានផលទៅលើអាការៈស្រៀវ ធ្មេញដែលកើតចេញពីការស្រុតចុះនៃអញ្ចាញធ្មេញតែប៉ុណ្ណោះ ។

**2-**ប្រសិនបើអ្នកមានអាការៈស្រៀវធ្មេញ មិនគួរទទួលទានអាហារ និងភេសជ្ជៈដែលមានសភាពត្រជាក់ ឬក៏ក្តៅពេកនោះទេ ព្រោះវានឹងបង្កើនការឈឺចាប់ដល់អ្នកបានកាន់តែខ្លាំងឡើងថែមទៀត។

**3-**អ្នកគួរប្រើច្រាស់ដុះធ្មេញដែលមានរោមទន់ដុះដោយសន្សឹមៗនៅលើសាច់ធ្មេញ មិនគួរដុះធ្ងន់ដៃ ព្រោះទង្វើនេះនឹងធ្វើឱ្យសារជាតិស្រោបសាច់ធ្មេញសឹកបានកាន់តែរហ័សឡើង ។



**4-**ប្រសិនបើអ្នកត្រូវការបំបាត់អាការៈស្រៀវធ្មេញបែបភ្លាមៗនោះ ចំណុចនេះយើងសូមណែនាំ ឱ្យអ្នកទៅជួបនឹងទន្តពេទ្យតែម្តង ព្រោះថា ពេទ្យធ្មេញគេអាចជួយអ្នកបានយ៉ាងល្អបំផុត ។

គ្រូពេទ្យធ្មេញនឹងណែនាំប្រើវិធីស្រោបធ្មេញបែបលក្ខណៈពិសេស ព្រមទាំងការពារធ្មេញរបស់អ្នកបាន ។ ប្រសិនបើអ្នកអនុវត្តបានវិធីណែនាំ ដូចបានពោលមកខាងលើនេះហើយនោះ អាការៈស្រៀវធ្មេញនៅតែមិនបាត់មធ្យោបាយដ៏ល្អបំផុត ចុងក្រោយគេ គឺជួបពិគ្រោះជាមួយគ្រូពេទ្យធ្មេញជាបន្ទាន់ ៕

# (តមកពីទំព័រទី០១) សាខាគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី...



លោក ញ៉យ ចំរើន

ដឹកនាំដោយលោក មាស ជា បានបើកកិច្ចប្រជុំរួមគ្នាមួយ ដើម្បីពិភាក្សាប្តូរយោបល់គ្នា និងដើម្បីផ្សាភ្ជាប់ចំណងសម្ព័ន្ធភាពប្រជាធិបតេយ្យរវាងគណបក្សប្រឆាំងទាំងពីរ បន្ទាប់ពីគណបក្សទាំងពីរបានប្រកាសជាផ្លូវការក្នុងការចងសម្ព័ន្ធភាពផ្នែកនយោបាយជាមួយគ្នា នាពេលកន្លងមកនេះ ។

អង្គមិទ្ទិញត្រូវបានប្រារព្ធធ្វើឡើងនៅរសៀលថ្ងៃអាទិត្យ ទី១៥ កុម្ភៈ ឆ្នាំ២០០៩ នៅឯព្រះវិហារគ្រីស្ទសាសនាខ្មែរមួយកន្លែងស្ថិតនៅក្នុងទីក្រុងហ្វីឡាដែលហ្វីហ្សៀខាងត្បូង ដោយមានសមាជិក សមាជិកាគាំទ្រគណបក្សទាំងពីរប្រមាណជា២០រូប ព្រមទាំងអ្នកឯករាជ្យមួយចំនួនទៀត ។

លោក ញ៉យ ចំរើន អតីតប្រធានចលនានិស្សិតដើម្បីប្រជាធិបតេយ្យ នៅឯប្រទេសកម្ពុជា ហើយបច្ចុប្បន្នជាថ្នាក់ដឹកនាំរបស់សាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋ ផែនស៊ីវ៉ៃនៀ បានធ្វើសេចក្តីថ្លែងការណ៍ជូនអង្គពិធីស្តីពីស្ថានការណ៍ថ្មីៗជុំវិញការរីកចម្រើនរបស់គណបក្សសិទ្ធិមនុស្សនៅឯប្រទេសកម្ពុជា និងនៅឯបរទេស ។ ទាក់ទងនឹងខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះ លោក ញ៉យ ចំរើន បានមានប្រសាសន៍ថា : បច្ចុប្បន្នគណបក្សសិទ្ធិមនុស្សបាននឹងកំពុងតែទទួលរងនូវការគាបសង្កត់ពីសំណាក់ក្រុមអ្នកមានអំណាចយ៉ាងខ្លាំង ប៉ុន្តែស្ថិតក្រោមការដឹកនាំរបស់លោកប្រធាន កឹម សុខា លោកនៅបន្តធ្វើសកម្មភាពប្រជាធិបតេយ្យដោយពុំញញើតញញើមឡើយ ។

ចំណែកលោក មាស ជា ដែលជាប្រធានសាខាគណបក្ស សម រង្ស៊ី ប្រចាំរដ្ឋផែនស៊ីវ៉ៃនៀ ដែរនោះ បានថ្លែងអំពីជោគជ័យរបស់គណបក្ស សម រង្ស៊ី នាឱកាសនោះថា : បច្ចុប្បន្នថ្នាក់ដឹកនាំរបស់គណបក្ស សម រង្ស៊ី មានតួនាទីក្នុងរដ្ឋាភិបាលយ៉ាងសន្ធឹកសន្ធាប់ ជាពិសេសនៅតាមមូលដ្ឋានមានស្ទើរតែទូទាំងប្រទេសហើយ ។ លោកបន្តថា : នេះគឺជាសញ្ញានៃភាពជោគជ័យរបស់គណបក្ស សម រង្ស៊ី ក្នុងការបោះឆ្នោតជាសកលមួយនៅឆ្នាំ២០១២ ខាងមុខនេះ ។



លោក មាស ជា

ក្នុងគ្រាដំណាលគ្នានោះផងដែរ លោក មាស ជា បានសំដែងនូវអារម្មណ៍សប្បាយរីករាយចំពោះជំនួបប្រជុំថ្ងៃនេះ គឺចង់ឃើញបងប្អូនខ្មែរគ្រប់និន្នាការទាំងអស់ឱ្យមានការរួបរួមគ្នា មានការរាប់អាន និងឯកភាពគ្នា ដើម្បីឈានទៅរកប្រយោជន៍ជាតិជាចម្បង ។ លោកបន្ថែមថា : តទៅថ្ងៃមុខយើងនឹងមានការរួមគ្នា ព្រោះចរន្តអ្នកប្រជាធិបតេយ្យពុំអាចបែកគ្នាបានទេ ។

ទោះបីជាប្រធានសាលាគណបក្ស សម រង្ស៊ី រូបនោះ បានមានប្រសាសន៍ ពុំចំចំណុចក្តីតែអ្នកចូលរួមក្នុងអង្គមិទ្ទិញ បានកាត់យល់ថា នៅថ្ងៃអនាគតខាងមុខ គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស អាចនឹងផ្សាសាច់ផ្សាឈាមរលាយចូលគ្នាជាគណបក្សតែមួយបាន ។

សូមជម្រាបថា បើតាមការឱ្យដឹងពីថ្នាក់ដឹកនាំរបស់សាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋ ផែនស៊ីវ៉ៃនៀ បានប្រាប់ឱ្យខ្មែរប៉ុស្តិ៍ឱ្យដឹងថា : ជារៀងរាល់ខែ គណបក្សតែងតែមានការប្រារព្ធពិធីកិច្ចប្រជុំក្រោមប្រធានបទផ្សេងៗ ផ្តោតលើដំណើរការអភិវឌ្ឍន៍របស់គណបក្ស និងមានការរៃអង្គាសប្រាក់ឧបត្ថម្ភប្រចាំខែជួយសម្រួលដល់សកម្មភាពការងាររបស់គណបក្ស នៅឯប្រទេសកម្ពុជាផងដែរ ៕


